# ១– ប្រវត្តិភូមិកំពង់ក្រសាំង

## និទានដោយលោកគ្រូ លឹម គឹមអ៊ន់ [1]



1 នៅភូមិវាល ឃុំវាល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

ខ្ញុំមានរឿងមួយនិយាយទាក់ទងពីប្រវត្តិភូមិកំពង់ក្រសាំងតែមិនដឹងថាប្រវត្តិនោះពិតឬគេប្រឌិតនោះទេ។

គេថាកាលសម័យដើម អ្នករស់នៅស្រុកខ្មែរយើងច្រើនល្ងង់ល្ងិត និយាយពាក្យសំដីអីមិនសូវចេះច្បាស់លាស់។ ដល់អញ្ចឹង សម័យមានកំណែនពីរាជការហ្នឹង គេនាំគ្នាកេណ្ឌមនុស្សឲ្យទៅធ្វើនេះធ្វើនោះរកពេលរកស៊ីមិនបាន ហើយសម័យហ្នឹងមធ្យោបាយធ្វើដំណើរគ្មានអីទេ មានតែទូក ដល់ពេលប្រជារាស្ត្រនៅម្ដុំហ្នឹងក៏អត់បានរកស៊ីរកអីដែរ ព្រោះធុញថប់នឹងគេកេណ្ឌទៅធ្វើការផង។

ថ្ងៃមួយគេក៏រើសបានពងក្រៀលមួយហើយគិតថា៖ "បើសិនជាយើងយកទៅថ្វាយស្ដេច ហើយសុំឲ្យរួចកំណែន ប្រហែលជាគ្រាន់បានពេលរកស៊ី!"

អញ្ចឹងក៏គិតគ្នាថាយកពងក្រៀលហ្នឹងទៅថ្វាយស្ដេច រួចសុំឲ្យរួចកំណែន។ ពួកគេបានចាត់បុរសម្នាក់ដើម្បីទៅគាល់ព្រះរាជា ប៉ុន្តែដោយគិតថាខ្លួនមិនសូវចេះនិយាយ ម្យ៉ាងខ្លាចអំណាចព្រះរាជាផង អញ្ចឹងមិនទុកចិត្ត បុរសនោះក៏ហៅគ្នា២នាក់ទៀតទៅជាមួយ។ ស្រុះស្រួលគ្នាហើយក៏នាំគ្នាឡើងទូកទៅ។ អុំទូកបានបន្តិចបុរសម្នាក់និយាយឡើង៖ "អញភ័យណាស់មិនដឹងជានិយាយដូចម្ដេចឲ្យសមទេនៀក!"

លុះអុំទូកទៅជិតដល់វាំង មិនអស់ចិត្តបុរសនោះក៏ផ្ដាំទៅគ្នាម្នាក់ទៀតថា៖ "បើអញនិយាយខុស ចាំជួយជ្រោមជ្រែងអញផង!"

អ្នកទី២មិនសូវទុកចិត្តខ្លួនឯងទៅទៀតក៏ផ្ដាំទៅអ្នកទី៣បន្តថា៖ "បើអញនិយាយខុស អ្ហែងចាំជួយជ្រែងទល់អញផង!"

លុះទៅដល់ អ្នកទាំងបីក៏ចូលទៅថ្វាយបង្គំស្ដេច។ ថ្វាយបង្គំស្រួលបួលហើយ ស្ដេចក៏សួរថា៖ "មាន

ការអី?" គ្រាន់តែស្ដេចសួរប៉ុណ្ណឹង ម្នាក់ៗក៏ភ័យញ័រពោះ ហើយបុរសទី១ក៏ឆ្លើយទាំងភិតភ័យថា៖ "ប្រទានពងគ្រេល ក្រាបទូល!"

ស្ដេចស្ដាប់មិនច្បាស់ គិតមិនយល់ថាប្រទានពងគ្រេល តែយល់ថាប្រទានពងក្រែល ក៏មើលទៅពងតែឃើញតែមួយទើបស្ដេចសំឡុតសួរថា៖ "ប្រទានពងក្រែល ម្ដេចក៏ឃើញតែមួយ!"

បុរសទី២ដែលចាំជួយនិយាយជ្រោមជ្រែង ដឹងថាបុរសទី១និយាយខុស ហើយឮព្រះរាជាសំឡុតសួរដូច្នេះក៏ទូលស្ដេចទាំងញ័រមាត់ថា៖ "ទានពងជ្រោមជ្រែង!"

ស្ដេចសម្ងំមុខទាំងឆ្ងល់ៗ បុរសទី៣ដែលចាំជួយនិយាយជ្រោមជ្រែងទល់ឮបុរសទាំងពីរនិយាយខុស ហើយក៏តបទាំងភ័យទៀតថា៖ "មិនមែនទេព្រះអង្គ គឺមកប្រទានពងជ្រែងទល់ទេ!"

ស្ដេចយល់ការណ៍ថា បុរសទាំងបីនាក់នេះភ័យហើយក៏មិនយកក្ដីអ្វីទាំងអស់ រួចមានបន្ទូលថា៖ "ឥឡូវពងស្អីក៏ស្អីទៅ! តើអ្នកមកប្រាថ្នាអ្វី?"

អ្នកទាំងបីទូលថា៖ "ប្រាថ្នាចង់ធ្វើធំ!"

ស្ដេចសួរថា៖ "ធ្វើធំប៉ុណ្ណា?"

អ្នកទាំងបីឆ្លើយ៖ "ធ្វើធំប៉ុនហ្លួង!"

ពេលនោះស្ដេចក៏យល់សាច់ការណ៍ថាអ្នកទាំងបីនេះមកចង់រួចកំណែនទេ អញ្ចឹងក៏ឲ្យគេយកក្រដាសមួយមកចារនិងវាយត្រាហើយផ្ដាំទៀតថា៖ "អ្នកទាំងបីយកក្រដាសនោះទៅបង្ហាញរាជការទៅ គេនឹងឈប់ប្រើហើយ! បើបាត់ក្រដាសហ្នឹង ត្រូវរកក្រដាសផ្សេងមក ហើយយកសំបកក្រសាំងមកដាក់ឲ្យក្រហមៗដូចជាត្រា

ទៅ ក៏គេឈប់ប្រើដែរ ប្រាប់ហេតុផលគេទៅ!"

ឮដូច្នេះ អ្នកទាំងបីអរកេខិបកខុប រួចក៏នាំគ្នាចុះទូកដែលចតត្រង់មុខវាំងត្រលប់វិញ។ ត្រង់នោះទឹកវាជ្រៅ ពេលឡើងមកដល់ក្នុងទូក ក៏ដណ្ដើមគ្នាមើល ព្រោះមិនដែលឃើញសំបុត្រស្ដេច។

អ្នកមួយថា៖ "មកអញមើលផង!"

អានេះថា៖ "អញមើលផង!"

ទាញចុះទាញឡើងរហូតទាល់តែសំបុត្រនោះជ្រុះទៅក្នុងទឹក ហើយនាំគ្នាគិតចុះរាវរក។ តែទឹកជ្រៅណាស់ បុរសម្នាក់ក៏និយាយថា៖ "ល្ងង់ណាស់! បើជ្រុះកន្លែងណាយកកាំបិតមកកាត់គែមទូកចំណាំ ចាំយើងទៅដល់ទីទឹករាក់ សឹមយើងចុះរកឲ្យចំកន្លែងជ្រុះហ្នឹង បើចុះរកកន្លែងហ្នឹងខ្លាចលង់ទឹកងាប់!"

ស្រុះស្រួលគ្នាហើយ ពួកគេក៏នាំគ្នាអុំទូកមកដល់កំពង់មួយ។ ពេលមកដល់ ម្នាក់និយាយឡើង៖ "យើងរកសំបុត្រឲ្យហើយ ជ្រុះត្រង់ណាអម្បាញ់មិញ?"

ពួកគេក៏នាំគ្នាដើរមើលទូករកកន្លែងកាប់ចំណាំ។ ឃើញទីចំណាំលើគែមទូក ម្នាក់លាន់មាត់ឡើង៖ "ជ្រុះត្រង់ហ្នឹងហើយ យើងចុះរាវរកមើល!"

រួចអ្នកទាំងបីក៏នាំគ្នាចុះរាវរកសំបុត្រទៅ។ ដល់រកយូរៗទៅ នៅតែរកសំបុត្រមិនឃើញ។ រកៗទៅ រាវៗទៅ ដល់ជិតអស់ចិត្ត ក៏រាវប៉ះនឹងសំបកក្រសាំងដែលគេចាក់ចោលមួយគំនរនៅត្រង់កំពង់នោះ ទើបនឹកឃើញរឿងស្ដេចផ្ដាំ ក៏យកសំបកក្រសាំងនោះមក រួចនាំគ្នារកស្អីក្រហមៗមកលាបលើសំបកក្រសាំងធ្វើជាត្រាវាយលើក្រដាស ហើយយកទៅបង្ហាញប្រាប់ហេតុផលគេ ទើបគេឈប់ប្រើមែនព្រោះយល់ថាពួកគេបានរួច

កំណែនពីព្រះរាជា។ ដោយនឹកឃើញថាកំពង់ហ្នឹងវាជួយដោះទាល់ឲ្យពួកគេ ទើបគេក៏ឲ្យឈ្មោះភូមិហ្នឹងថា**ភូមិកំពង់ក្រសាំង**ៗ រហូតមក។ បច្ចុប្បន្នភូមិនេះឋិតនៅ ឃុំវាល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់៕

# ២- ប្រវត្តិអង្គនានានៅខេត្តតាកែវ

## និទានដោយលោកតា ឆាយ កង [2]

*អង្គជាឈ្មោះអ្វីលោកតា? ហេតុអីបានជាមានអង្គច្រើនម្ល៉េះលោកតា? ម៉េចបានជាគេដាក់ឈ្មោះអញ្ចឹង?*

*អង្គមានឈ្មោះច្រើនដូចជា អង្គរកា អង្គតាចាន់ អង្គរលួស អង្គសំរោង អង្គនារាយណ៍ អង្គក្ដីចាស់ អង្គតាបិត អង្គតាប៊ួយអីហ្នឹង។*

*ឈ្មោះអង្គហ្នឹង គេយកតាមឈ្មោះអ្នកដែលមកកាន់កាប់នៅទីកន្លែងនោះមុនគេ ពីព្រោះប្រទេសយើងពីដើមក្រមនុស្សណាស់។ ខ្ញុំដឹងតាមចាស់ៗនិទានមកថា អ្នកជីកអង្គហ្នឹងគឺព្រះបាទដៃខ្វី។ រឿងនោះនិទានថាព្រះបាទដៃខ្វីហ្នឹងជាកូនរបស់នាងសក់ក្រអូបនិងព្រះបាទបាយ៉ង់កោរ។ ពេលនោះស្ដេចសៀមឮល្បីពីនាងសក់ក្រអូបខ្លាំងពេក ក៏នាំពួកកងយោធាសេនាទាំងអស់ចុះសំពៅមកតាមរកនាងសក់ក្រអូប។ ពេលមកដល់ ស្ដេចបញ្ជាកងសេនាថា៖ "បើកាលណានាងសក់ក្រអូបចូលមកមើលល្ខោនដល់ក្នុងសំពៅ ហើយពេលអ្នកភ្លេងចាប់ផ្ដើមលេងភ្លេងពិណពាទ្យ សំពៅត្រូវចាប់ថយពីច្រាំងទៅ!"*

*ដូចនេះទើបបានជាយើងមានភ្លេងសំពៅថយតាំងពីពេលនោះមក។*

*បើអញ្ចឹងគេចាំមើល។ ដល់ពេលរាត្រីយប់ប្រហែលម៉ោង១២ នាងសក់ក្រអូបក៏ចូលទៅមើលល្ខោន។ ស្ដេចសៀមដឹងថានាងសក់ក្រអូបចូលមកដល់ ក៏បញ្ជាឲ្យអ្នកភ្លេងលេងបទសំពៅថយ។ សំពៅកាត់ខ្សែថយ*

---

2 *នៅភូមិអង្គតាចន្ទ័ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។*

រឹង ក៏នាំយកនាងសក់ក្រអូបទៅស្រុកសៀមបាត់។

លុះកូនឈ្មោះព្រះបាទដៃខ្វីហ្នឹងធំឡើងអាយុបាន១៨ឆ្នាំ ក៏សួរទៅព្រះបិតាថា៖ "តើព្រះមាតាទៅណា ហេតុដូចម្ដេចបានជាកូនមិនដែលឃើញព្រះមាតាសោះដូច្នេះ?"

ព្រះបាទបាយ៉ង់កោរជាឪពុកក៏ប្រាប់ថា៖ "ព្រះមាតា! នាងសក់ក្រអូបរបស់កូនត្រូវសៀមចាប់យកទៅស្រុកវាហើយ!"

ព្រះបាទដៃខ្វីលោកជ្រាបរឿងនេះក៏នាំទ័ពទៅត្រឹមព្រំដែនសៀម ហើយក៏ចូលទៅរកមាតាតែម្នាក់ឯង។ ព្រះបាទដៃខ្វីចូលទៅ ក៏ទៅជួបព្រះមាតានៅក្នុងប្រាសាទមួយ តែទ្រង់ឥតស្គាល់ថាជាព្រះមាតាខ្លួនឡើយ។ ឯនាងក៏មិនស្គាល់ថាជាកូនខ្លួនដែរ។ កាលបើឃើញនាងសក់ក្រអូបមានសម្រស់ស្រស់ស្អាតដូច្នេះ ព្រះបាទដៃខ្វីក៏សួរទាក់ទងស្រលាញ់ស្នេហាគ្នាហើយក៏បាននាំនាងចេញមកខាងក្រៅដើម្បីទៅថ្វាយបង្គំព្រះបិតា។ ពេលមកដល់ព្រះបិតាបានស្គាល់ថាជាមហេសីរបស់ខ្លួនក៏ប្រាប់ទៅកូនវិញថា៖ "នាងត្រូវជាម្ដាយរបស់កូនឯងទេ!"

កាលនាងសក់ក្រអូបជាម្ដាយដឹងថាព្រះបាទដៃខ្វីជាកូនរបស់ខ្លួន នាងមានការសោកស្ដាយណាស់ក៏បានបង្គាប់ព្រះបាទដៃខ្វីឲ្យជីកអន្លង់ឲ្យបាន១០០០អន្លង់នៅក្នុងខេត្តតាកែវនេះ ដើម្បីលុបលាងកំហុសដោយសន្មត់ថាកាលណាអន្លង់ទាំងនោះក្លាយមកជាជីរាបស្មើនឹងដីរាបធម្មតាវិញ ទើបកូនរួចទោសកំហុសដែលបានស្រលាញ់ម្ដាយរបស់ខ្លួន។ កាលដែលព្រះបាទដៃខ្វីសាងអន្លង់ដំបូង គេមិនទាន់ដាក់ឈ្មោះអន្លង់នៅឡើយទេ។ ឈ្មោះអន្លង់ផ្សេងគ្នានេះ កើតឡើងដោយសារតែគេយកតាមឈ្មោះលោកតាឬអ្នកដែលមកកាន់កាប់ដីអន្លង់នោះមុនដំបូងគេ។ អញ្ចឹងហើយបានជាកូនចៅជំនាន់ក្រោយមកនាំគ្នាហៅថាអន្លង់តាចាន់ អន្លង់តាមោក អន្លង់តាសេះជាដើម៕

# ៣- ប្រវត្តិវត្តប៉ាហ៊ី

## និទានដោយព្រះតេជគុណ អៀ សុផន [3]

*វត្តនេះតំណាលតាំងពីពេលដែលគេទើបតែធ្វើសាលាហ្នឹងថា ពីដើមដីម្ដុំហ្នឹងមានដើមឈើធំៗច្រើនណាស់ ហើយក៏មានគេជីកត្បូងម្ដុំនឹងច្រើនដែរ។ គេជីកនៅខាងក្រោមអូរ ហើយក៏រែងត្បូងនៅក្រោមអូរនោះដែរ។ អ្នកនៅខាងលើក៏ជីកត្បូងដែរ ជីកនៅត្រង់នោះឯង រួចគេក៏ធ្វើសាលាមួយ។*

*ថ្ងៃមួយដល់ជីកទៅ មានស្រីៗគេមកជីកត្បូងកន្លែងហ្នឹង។ ធម្មតាប្រុសៗដើរទៅមកតាមផ្លូវហ្នឹង ក៏ឃើញស្រីម្នាក់នៅម្នាក់ឯង។ ពេលមកដល់ក្នុងព្រៃម្ដុំហ្នឹង ឃើញស្រីកំពុងជីកត្បូងម្នាក់ឯងក៏មានតម្រេកតណ្ហាកើតឡើង មើលឆ្វេងស្ដាំទៅ មិនឃើញមានមនុស្សក៏ចាប់នាងហ្នឹងនៅកន្លែងនោះតែម្ដង។ ដល់ក្រោយមក គេក៏ដឹងឮទៅបានគេដាក់ព្រៃហ្នឹងថា**ប៉ាហ៊ី**។ តាមភាសាកូឡា**ប៉ាហ៊ី** ប្រែថា**សួស្ដី**។ តែអាត្មាអត់ចេះភាសាកូឡាទេ ឮតែតាមចាស់និយាយមិនដឹងពិតឬក៏មិនពិតខុសឬត្រូវទេ។ តែតាមពិត**ប៉ាហ៊ី**នេះជាភាសាថៃទេ។ **ប៉ា**ប្រែថា/ព្រៃ ឯ**ហ៊ី**ប្រែថា/យោនីរបស់ស្ដ្រី។ សរុបទៅព្រៃនេះឈ្មោះថា**ព្រៃយោនី**ហ្នឹងឯង។ អញ្ចឹងបានហៅតគ្នារហូត។ ដល់ពេលក្រោយមកតំបន់ហ្នឹង ពួកជនជាតិកូឡាគេឈប់ឲ្យជីកត្បូង គេក៏ធ្វើជាវត្តឡើង។ វត្តនេះមិនមែនជាវត្តខ្មែរទេគឺជាវត្តជនជាតិកូឡាដែលកាន់ពុទ្ធសាសនាដូចគ្នា។ គេដាក់ឈ្មោះវត្តនេះតាមឈ្មោះព្រៃហ្នឹងជាប់រហូតមកទៅគឺ**វត្តប៉ាហ៊ី**។ តែសព្វថ្ងៃនេះគេដូរដាក់ឈ្មោះថា**វត្តកូឡា**ស្ថិតនៅក្នុងភូមិប៉ាហ៊ី សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន៕*

---

3 *លោកគង់នៅ វត្តប៉ាហ៊ី ភូមិប៉ាហ៊ី សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន។*

# ៤- ភូមិឧបរាជ និង កំណើតវត្តញ្ញៅ

## និទានដោយ លោកតាថោង ហ៊ុំ [4]

*ក្នុងភូមិសំរោងខ្នុរ ឃុំសំរោងក្នុង មានរឿងនិទានស្ដីពីកំណើតភូមិនិងវត្តមួយដែលមានតំណាលថាប្រហែលជា៣០០ឆ្នាំមុន មានអ្នកបម្រើស្ដេចម្នាក់ដែលមានបុណ្យសក្តិធំមានមុខនាទីជាឧបរាជ។ លោកឧបរាជហ្នឹងក៏ជាស្ដេចក្រាញ់តាមភូមិភាគនៃខេត្តនីមួយៗដែរ។ លោកឧបរាជនោះមានឈ្មោះថា* ***លោកឧកញ៉ាឧបរាជសឿន*** *។ នៅជំនាន់នោះ លោកឧបរាជរូបនេះបានចិញ្ចឹមដំរីជាច្រើនក្បាល សម្រាប់ធ្វើជាកម្លាំងអូសទាញឈើហុប ឬក៏យកទៅធ្វើជាជំនិះរបស់ទ័ពសម្រាប់ចេញច្បាំងជាដើម។ ថ្ងៃមួយគាត់បានធ្វើដំណើរឆ្លងកាត់តំបន់មួយគាត់ក៏ឃើញទីទួលមួយដែលអាចយកដំរីមកចិញ្ចឹមបំប៉នចំណីនៅទីនេះបាន។ រួចគាត់ក៏ចាត់ឲ្យទម័កដំរីម្នាក់ឈ្មោះ* ***នៅ*** *នាំដំរីយកមកចងនៅលើទួលនោះគឺទួលវត្តញ្ញៅសព្វថ្ងៃនេះ។ ចំណែកតា* ***នៅ*** *និងអ្នកដែលជាទម័កដំរីដទៃទៀតវិញ លោកឧបរាជគាត់បានចាត់ឲ្យនៅទួលមួយនៅជាប់នោះដែរ។ លុះនៅយូរទៅ ក៏កកើតជាភូមិមួយ អ្នកភូមិក៏នាំគ្នាដាក់ឈ្មោះភូមិនោះថាភូមិ* ***ឧបរាជ*** *តាមឈ្មោះរបស់លោកឧបរាជដែលមានអំណាចនិងមានគុណបំណាច់សណ្ដោសដល់អ្នកទម័កដំរីទាំងនោះ។ ប៉ុន្ដែតមក អ្នកស្រុកហៅឧបរាជមិនត្រូវ ចេះតែក្លាយរហូតមកដល់សព្វថ្ងៃ ហើយបែរជាជាប់ឈ្មោះថាភូមិ* ***បវរាជ*** *ទៅវិញ។*

*ចំណែកតានៅនិងទម័កដំរីដែលជាអ្នកបម្រើទទួលខុសត្រូវរឿងដំរីនេះវិញ មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធ*

---

4 *ភូមិសំរោងស្នោ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។*

សាសនាណាស់។ ពេលគាត់យកដំរីមកចងលើទួលនេះយូរៗទៅ គាត់ក៏ប្រមូលបានអ្នកធ្វើបុណ្យអ្នកធ្វើទានជាច្រើននាក់ដើម្បីជួយកសាងវត្តមួយលើទួលហ្នឹង។ មុនដំបូងសាងជារោងឧបោសថទៅនៅក្នុងព្រៃល្វា។ លុះមានកុដិមានអាស្រមអីរួចក៏នាំពុទ្ធបរិស័ទមកសមាទានសីលនៅកន្លែងទួលហ្នឹង។ ដូច្នេះតំណតមកទៀតមក អាស្រមនោះក៏បានក្លាយទៅជាវត្តមួយពេញលក្ខណៈតាមប្រពៃណីរបស់ពុទ្ធសាសនាយើង ដោយមានកសាងជាព្រះវិហារហើយនិងមានពិធីអភិសេកព្រះពុទ្ធយ៉ាងត្រឹមត្រូវ។ អ្នកភូមិបវរាជទាំងអស់ដែលជាពុទ្ធបរិស័ទចំណុះជើងវត្តក៏នាំគ្នាដាក់ឈ្មោះវត្តហ្នឹងថា**វត្តតានៅ** ដោយយោងថា**តានៅ**ជាអ្នកមានគំនិតបង្កើតវត្តនេះមុនគេ។ ដល់ពេលយូរៗមក**វត្តតានៅ**ក៏ប្រែក្លាយឈ្មោះពី**វត្តតានៅ**មកជា**វត្តញ្ញៅ** រហូតមកដល់សព្វថ្ងៃនេះ។

នៅខាងក្រោយភូមិបវរាជនេះ លោកឧបរាជក៏បានបង្កើតភូមិមួយទៀតឡើងដែរ ដោយយកអ្នកស្រុកដែលមានគុណបំណាច់ ឬ អ្នកទោសដែលលោកលើកលែងទោសរួច ឲ្យទៅនៅភូមិមួយថ្មីនោះ។ លុះកកើតជាភូមិមួយហើយ អ្នកស្រុកកកើតកូនពូនជាចៅប្រកបរបរផ្សេងៗ ដែលពីដើមតាមធម្មតាគេប្រកបរបរ បរបាញ់សត្វរកនេសាទត្រី និងធ្វើស្រែចំការជាដើម៕

# ៥- វត្តពោធិ៍មានបុណ្យ ភូមិព្រះមិននៅ និង ស្រុកបាកាណ

**និទានដោយលោក ម៉ៅ សោភ័ណ [5]**

*ពោធិ៍មានបុណ្យហ្នឹងវាមានរឿងតំណាលអញ្ចេះ ៖*

*ដើមពោធិ៍ហ្នឹងមានបុណ្យ មិនដឹងជាហេតុអី បានជាដើមពោធិ៍នោះសុគតទេ។ នៅពេលដែលព្រះអង្គច័ន្ទរាជាយាងមកពីលង្វែកនាពេលល្ងាចប្រហែលជាម៉ោង៣រសៀល ព្រះអង្គបានបោះជំរំនៅនឹងបន្ទាយជ័យចាស់។ មកដល់ទីនេះ ដើមពោធិ៍ចាប់ញ័រកំរើកដុះពន្លកត្រួយឡើងវិញ។ ឃើញដើមពោធិ៍អញ្ចឹង ព្រះអង្គនឹកឃើញថា៖ "អូ! បើអញ្ចឹងការធ្វើសង្គ្រាម ការឈ្លោះប្រណាំងប្រជែងរវាងខ្មែរនិងសៀម ប្រហែលជាត្រូវចាញ់លោក ដោយសារចាញ់បារមីរបស់លោកហើយ!"*

*ក្រោយមក លោករៀបចំបោះព្រះពន្លាជ័យនៅបន្ទាយជ័យនោះ ទើបគេហៅថាបន្ទាយជ័យខេត្តពោធិ៍សាត់ទៅ។ ដល់ព្រះអង្គច័ន្ទរាជាលោកមកបោះព្រះពន្លានៅត្រង់កន្លែងដើមពោធិ៍កណ្ដាលបន្ទាយជ័យ គេក៏ត្រៀមលក្ខណៈត្រៀមដំរីទៅប្រជល់ប្រណាំងជាមួយដំរីរបស់ព្រះសទ្ធានរាជាពញ៉ាអុង។ តាមពិតព្រះសទ្ធានរាជាពញ៉ាអុងក៏ជាខ្មែរដែរ តែរត់ទៅនៅផ្ញើខ្លួនផ្ញើប្រាណជាមួយព្រះចៅក្រុងទេពបុរីឯស្រុកសៀមជាមួយព្រះអង្គច័ន្ទរាជា។ ដល់យូរៗទៅ ព្រះអង្គគិតលែងចង់មកស្រុកវិញ។ ក្រោយមកព្រះអង្គច័ន្ទរាជាលាស្ដេចសៀមមកស្រុកខ្មែរដើម្បីទាក់ដំរីសថ្វាយដល់ព្រះចៅក្រុងទេពបុរី តែតាមពិតព្រះអង្គច័ន្ទរាជាមកធ្វើសង្គ្រាមវាយជា*

5 *ភូមិកំពែងស្វាយ ឃុំស្នាមព្រះ ស្រុកបាកាណ ខេត្តពោធិ៍សាត់។*

មួយស្ដេចកនហើយមានជ័យមានជោគ។ បាត់ដំណឹងអង្គច័ន្ទរាជាមិនឃើញមកគាល់យកសួយសារអីមកថ្វាយព្រះចៅក្រុងទេពបុរីស្រុកសៀម ក៏ដេញឲ្យព្រះសទ្ធានរាជាពញ៉ាអុងដឹកនាំទ័ពមកតាមព្រះច័ន្ទរាជា។ ពីដំបូងព្រះសទ្ធានរាជាពញ៉ាអុងបោះទីតាំងពីខាងលិចស្វាយដូនកែវ ដើម្បីចរចារតាមរយៈការផ្ញើរាជសារទៅឲ្យព្រះច័ន្ទរាជា។ បន្ទាប់មក ដោយសារព្រះអង្គចន្ទរាជាដឹងច្បាស់នូវនិស្ស័យរបស់ព្រះសទ្ធានរាជាពញ៉ាអុងគ្មានពូកែខាងរឿងច្បាំងទេ ហើយព្រះអង្គមិនចង់ចេញច្បាំងផង ព្រះអង្គក៏គិតបបួលព្រះសទ្ធានរាជាពញ៉ាអុងប្រណាំងប្រជល់ដំរីគ្នាឲ្យដឹងឈ្នះដឹងចាញ់។ បើព្រះអង្គច័ន្ទរាជាចាញ់ ព្រះអង្គសុខចិត្តនាំសួយសារយកទៅថ្វាយ។ ដូច្នោះព្រះអង្គទាំងពីរក៏ណាត់ពេលវេលា និងទីកន្លែងដើម្បីប្រជល់ដំរីគ្នា។ ព្រះអង្គច័ន្ទរាជាធ្វើពិធីប្រជល់ដំរីបានជ័យជំនះរហូតដល់ព្រះសទ្ធានរាជាពញ៉ាអុងសុគតនៅឯវាលព្រះម្ហូ។

ដោយព្រះអង្គច័ន្ទរាជានឹកអាណិតដល់ព្រះសទ្ធានរាជាពញ៉ាអុង ក៏លើកយកសពរបស់ព្រះសទ្ធានរាជាពញ៉ាអុងមកធ្វើបុណ្យតាមគន្លងប្រពៃណីទៅ ព្រោះខ្មែរដូចគ្នានឹកស្រណោះគ្រាដែលធ្លាប់ទៅរស់នៅជាមួយគ្នានៅក្នុងក្រុងទេព។ ព្រះអង្គយកសពព្រះសទ្ធានរាជាពញ៉ាអុងមកតម្កល់ទុកនៅក្នុងបន្ទាយហ្នឹង។ កាលនោះមិនទាន់មានឈ្មោះថាវត្តអីទេ គ្រាន់តែយកសពហ្នឹងមកតម្កល់ទុកធ្វើព្រះមេរុដើម្បីត្រៀមលក្ខណៈបូជាសពព្រះសទ្ធានរាជាពញ៉ាអុង។ ដល់បូជាសពហើយ ព្រះច័ន្ទរាជាយកពានព្រះស្រី[6]របស់ព្រះពញ៉ាអុងកសាងព្រះពុទ្ធរូប ហើយពានព្រះស្រីរបស់ព្រះអង្គចន្ទរាជាធ្វើជាព្រះពុទ្ធរូបមាស បន្ទាប់មកព្រះច័ន្ទរាជាបញ្ជាឲ្យគេធ្វើវិហារឈើប្រក់ស្បូវមួយ ធ្វើកុដិមួយ សាលាឆាន់មួយ ហើយឧបជិកកន្លែងនោះឲ្យក្លាយទៅជាវត្តមួយ។ ព្រះអង្គច័ន្ទ

---

6 *ពានព្រះស្រី* ជារាជសព្ទមានន័យថាពានដាក់ស្លា បារី។ ធន់ ហ៊ិន *រាជសព្ទក្នុងភាសាខ្មែរ* ២០០៣ បោះពុម្ពលើកទី២ ទំព័រ២០។

រាជាលោកសព្វព្រះទ័យអញ្ចឹងក៏បានសុំយកនាមវត្តនោះថា *វត្តពោធិ៍មានបុណ្យ* ពីព្រោះពោធិ៍នោះស្លាប់អស់ទៅហើយបែរជាដុះពន្លកត្រួយទៅវិញ។ អញ្ចឹងក៏មានឈ្មោះថាវត្តពោធិ៍មានបុណ្យរហូតមកទល់សព្វថ្ងៃនេះ។

វាលព្រះម្លូនេះមានរឿងទាក់ទងនឹងព្រះពោធិ៍សោត់ដែរ។ ទីហ្នឹងមកពីពាក្យថា *ព្រះមិនទៅ* ដោយសារប្រជាជននាំគ្នាទៅទាក់ព្រះពោធិ៍ តែពោធិ៍នោះរសាត់រហូតមិនព្រមនៅសោះ រសាត់ទៅរហូតដល់ឧត្តុង្គ។ លុះដល់ឧត្តុង្គហើយមិនព្រមនៅ ទៅដល់លង្វែក ទៅដល់ចតុមុខៗបែរជារលើងឫសតាមទឹកជំនន់ ហើយរសាត់ឡើងតាមដៃទន្លេសាបហ្នឹងចូលមក។ ទីហ្នឹងវិញ ប្រុងសំដៅមកពោធិ៍មានបុណ្យហ្នឹង ប៉ុន្តែដូចជាវាមកមិនដល់ នាំគ្នាទាក់នៅក្រោមនៅកន្លែង*ចាជល់* ឡើងរហូតដល់ព្រះម្លូ មកដល់ព្រះម្លូនៅតែទាក់មិនជាប់ទៀត នោះទើបគេហៅថា*ព្រះមិនទៅ*។ អញ្ចឹងដើមពោធិ៍នោះរសាត់ឡើងរហូតមកដល់បាកាននេះ។ ពេលមកដល់បាកាននេះ អ្នកស្រុកក៏នាំគ្នាធ្វើពិធីបុណ្យបួងសួង សុំទាក់ដើមពោធិ៍មានបុណ្យនោះឲ្យទាល់តែជាប់ហើយក៏ទាក់បានដូចបំណងមែន។ ពេលទាក់ព្រះពោធិ៍បាន អ្នកស្រុកនាំគ្នាស្រែកជាសញ្ញាថាបានការហើយៗ ទើបទីនោះមានឈ្មោះថា*បានការ*។ ពាក្យនេះបើអានតាមសំនៀងថៃ ពេលអក្សរ "រ" ជាតួប្រកបវាត្រូវអានជាសំលេង"ន" ទើបពាក្យនេះក្លាយជាបានកាន។ តែឥឡូវស្រាប់តែក្លាយទៅជាបាកានវិញ[7]។ ចំនែកពាក្យថាពោធិ៍សាត់វិញ មិនមែន

7 តាមលោកគ្រូ លីម អ៊ិន់និយាយថាពាក្យ*បាកាន* នេះជាពាក្យគន្ទាស់មកពីពាក្យ*បានការ* វិញ។ លោកនិទានរឿងនេះថា នៅស្រុកបាកានពីមុនសម្បូរទឹកច្រើនជាងដី។ មានពេលមួយមានដើមពោធិ៍១ដើមធំរសាត់បញ្ច្រាស់ទឹកមក។ អ្នកស្រុកឃើញដើមឈើធំដូច្នេះនឹកប្លែកក៏នាំគ្នាយកពួរយកព្រ័តទៅទាក់ចងដើមពោធិ៍ហ្នឹងទុក។ ទោះបីជាទាក់ចងយ៉ាងណាក៏ដោយ ក៏គេមិនអាចទាក់ដើមពោធិ៍នោះជាប់ឡើយ ហើយខ្សែពួរដែលគេយកទៅទាក់ចងនោះចេះតែដាច់រហូត ឯដើមពោធិ៍នោះក៏ចុះតែរសាត់ទៅ។ ពេលនោះមានតា

ត្រឹមតែពោធិសត្វទេគឺមកពីពាក្យពោធិ៍សាត់នេះឯង។

ព្រះអង្គច័ន្ទរាជាធ្វើចប់សព្វគ្រប់ហើយ ព្រះអង្គក៏យាងទៅក្រគរវិញដែលមានបន្ទាយមួយនៅក្បែរនោះ ព្រះច័ន្ទរាជាលោកយាងទៅសម្រាក់នៅក្នុងបន្ទាយនោះ។ ហើយព្រះអង្គរៀបចំទីក្បែរបន្ទាយនោះកសាងជាវត្ត មួយមាននាមហៅថា*វត្តក្រគ* ប៉ុន្តែមកទល់សព្វថ្ងៃនេះគេហៅថា*វត្តបន្ទាយក្រគ* ដោយសារគេឃើញវត្តនោះ នៅក្បែរបន្ទាយចាស់ពីដើម។ បន្ទាប់មកព្រះអង្គបានទៅកសាងវត្តហ្លួង វត្តព្រះពុទ្ធលាយលក្ខណ៍ បរិបូរណ៍ ចង្ហាន់ហុយ កសាងវត្តតៗរហូតបានដល់ឧត្តុង្គ នោះសម័យចតុមុខព្រះអង្គកសាងវត្តច្រើនណាស់៕

---

ចាស់ម្នាក់និយាយថា៖ "ចៅឯងយកខ្សែអីៗទៅចងដើមពោធិ៍ហ្នឹងមិនជាប់ទេ ចៅឯងទៅយកអំបោះពាសសែមក តានឹងចងឲ្យ!" គេក៏រត់ទៅយកខ្សែអំបោះពាសសែមកហុចឲ្យតាហ្នឹង។ តាក៏ឧបកិច្ចសំបូងសង្រ្វងទៅតាមវិធីរបស់គាត់ ហើយក៏បោះខ្សែអំបោះនោះទៅចងដើមពោធិ៍នោះស្រាប់តែចងជាប់។ អ្នកស្រុកឃើញដូច្នេះ ក៏នាំគ្នាអបអរសោទរហើយស្រែកថា៖"អឺ! បានការហើយយើង អញ្ចឹងបានជាគេដាក់ឈ្មោះទីនោះថាស្រុកបានការៗ"

លុះហៅយូរទៅវាក្លាយទៅជាបាកានវិញ។ គេទម្លាប់ហៅបាកានស្រួលជាងហៅបានការ ព្រោះបានការជាពាក្យពីរម៉ាត់ វាពិបាកហៅ ឯបាកានជាពាក្យគន្លាស់មួយម៉ាត់ ដូចជារអិលស្រួលហៅជាង។ អ្នកស្រុកនេះ ទម្លាប់ ហៅតែដូច្នេះឯងដូចភូមិសន្សា អញ្ចឹង ដំបូងគេថាសន្សាៗ លុះយូរៗទៅហៅញ៉ាប់ៗថាត្រឹមតែស្សាៗបាត់សូរសន់ទៅ។ រីឯឈ្មោះខេត្តពោធិ៍សាត់វិញ ដំបូងគេដាក់ឈ្មោះថាខេត្តពោធិ៍សាត់ទេ គឺគេយកតាមរឿងតំណាលខាងលើនេះឯង។

# ៦- រឿងភូមិដំរីស្លាប់

## និទានដោយមីងម្នាក់ [8]

*ភូមិដំរីស្លាប់ហ្នឹងនៅភូមិទ្រា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ ខ្ញុំឮអ្នកស្រុកចាស់និយាយកាលជំនាន់គេធ្វើសង្គ្រាមៗ និយាយពីដើមមក ដំរីនោះអត់មានអ្នកណាសម្លាប់វាទេតែវាស្លាប់ដោយខ្លួនឯងៗ*

*កាលនោះមានយាយតាពីរនាក់នាំគ្នាទៅដាក់អន្ទាក់នៅក្នុងព្រៃៗ ដល់ពេលបោចអន្ទាក់មក តាក៏ប្រាប់ប្រពន្ធគាត់ថា៖ "យាយ! យាយឯងដើរក្នុងព្រៃមើលឲ្យស្រួល ប្រយ័ត្នមានសត្វតូចសត្វធំអី!"*

*យាយនិងតាក៏ចេះតែលួសអន្ទាក់ខ្វាកៗទៅៗ ពេលនោះមានដំរីពីរក្បាលវាស្រលាញ់គ្នា ហើយវាមានតម្រេករកចង់គ្នានៅក្នុងព្រៃៗ ស្រាប់តែពេលនោះតាយាយនោះឃើញវាៗ ដំរីញីនោះឃើញដូច្នោះនឹកអៀនខ្មាសពេកណាស់ ក៏រត់ទៅបោលបោកគក់ដំរីឈ្មោល គក់មុាំងៗៗ ហើយដោយសារវាខឹងពេក ដំរីញីនោះក៏បែររត់ទៅដេញបោកយាយតាវិញម្ដង ព្រោះពួកគាត់ជាអ្នកឃើញខ្លួនវាៗ យាយតាក៏ស្ទុះរត់រកប្រាសអាយុរៀងខ្លួនទៅៗ ពេលយាយតារត់ៗបានដល់ពាក់កណ្ដាលផ្លូវ ក៏ចុះបែកផ្លូវគ្នារត់ៗ តាក៏បោះក្រមាមួយទៅលើដើមឈើហើយឡើងទៅលើដើមឈើនោះ ហើយយាយគាត់ក៏រត់ផុតដែរៗ និយាយពីអាដំរីឈ្មោលវិញ វាខឹងពេកក៏រត់ទៅគក់ៗមីញីវិញៗ មីញីគក់អាឈ្មោលរត់ ទាល់តែទៅដល់ដើមឈើៗ តាឃើញដូចនោះក៏ទម្លាក់ក្រមាឲ្យ*

---

*[8] មីងម្នាក់នេះមិនបានប្រាប់ឈ្មោះដល់ក្រុមសំភាសយើងខ្ញុំទេ គាត់នៅភូមិត្រពាំងជ្រៃ ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវៗ*

ដំរីបែនក្រមានោះៗ ឯដំរីញីវាអៀនដេញវាយអាឈ្មោលមិនបាន ហើយដេញតាមមនុស្សក៏មិនបានទៀត នឹកខឹងក៏បោកខ្លួនវាទាល់តែងាប់ ងាប់នៅជិតព្រៃបំពង់ឬស្សីៗ ឯដំរីឈ្មោលវិញវាអត់ស្លាប់ទេៗ

អាហ្នឹងពីដើម ដំរីវាអៀនណាស់ វាចេះស្រលាញ់គ្នាតែមិនដែលឲ្យមនុស្ស យើងឃើញវាទេៗ អញ្ចឹងបានជាមានឈ្មោះ**ភូមិដំរីស្លាប់**ដល់ពេលសព្វថ្ងៃនេះ៕

# ៧- រឿងកំណើតសត្វស្វា

លោកតាទូច កាយ [9]



9 នៅភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

ខ្ញុំនិយាយរឿងមួយចុះ និយាយពីរឿងកំណើតរបស់សត្វស្វា តើលោកក្មួយដឹងដែរឬទេអំពីកំណើតសត្វស្វានេះ?

ពួកខ្ញុំអត់ដឹងផងលោកតា!

រឿងហ្នឹងទាក់ទងដល់ការដាក់ទោសកំហុសមួយៗ បើតាមប្រពៃណីខ្មែរ ព្រះពុទ្ធសាសនាខ្មែរយើងអ្នកកាន់សីល កាន់ធម៌អាចឲ្យគេអត់បរិភោគបាយល្ងាចទេ។ ប៉ុន្តែរឿងនេះ និយាយពីយាយជី តាជីកាន់ឧបោសថ តែនៅក្នុងខ្លួនមានចិត្តមិនជ្រះថ្លានៅតែជាប់ជំពាក់មិនដាច់ពីលោភៈ ទោសៈ មោហៈ ទើបបានកើតជាសត្វស្វា។

បើគេនិយាយពីរឿងកំណើតសត្វស្វានោះ គេនិយាយពីចៅមាណពម្នាក់ៗ មានរឿងតំណាលថាចៅមាណពនោះជាអ្នកក្រលំបាកណាស់ អត់មានស្រែមានភ្លឺទេ។ បន្តិចក្រោយមក ចៅមាណពនោះក៏បានគ្រួសារមួយ។ លុះបានគ្រួសារទៅ ចៅមាណពនោះក៏អត់មានរកស៊ីអីដែរ ដឹងរកតែត្រីមួយមុខគត់សម្រាប់ចិញ្ចឹមគ្រួសារ។ ពីរបីឆ្នាំក្រោយមកគ្រួសារនេះកើតបានកូនប្រុសមួយ រួចក៏នាំកូនទៅរកស៊ីជាមួយដែរ គឺទៅរកតែត្រីហ្នឹងឯង ព្រោះមិនដឹងជារកស៊ីអ្វីផ្សេងក្រៅពីនេះ។

កាលនោះគេថាព្រះពុទ្ធនៅមានឡើយ ហើយមានតាជីនិងយាយជីមួយក្រុម តែងនាំគ្នាទៅធ្វើឧបោសថសីលមិនដែលខាន ។ ពេលទៅសុំសីលម្ដងៗ គាត់ក៏បបួលចៅមាណពថា៖ "ក្មួយអើយទៅវត្តទៅវ៉ា នឹងគេទៅ យើងចាស់ប៉ុណ្ណឹងហើយ ពាក់កណ្ដាលមនុស្សហើយ!"

ចៅមាណពតបវិញថា៖ "ខ្ញុំទៅមិនរួចទេ លោកយាយលោកតាអើយ! ខ្ញុំក្រលំបាកណាស់ រកមួយថ្ងៃសម្រាប់តែមួយថ្ងៃប៉ុណ្ណោះ បើទៅសុំសីលមិនដឹងថាបានអីចិញ្ចឹមជីវិតទេ?"

ថៅមាណពមិនព្រមទៅសុំសីលទេ ហើយនៅតែប្រកបរបរនេសាទជាប្រក្រតីជាមួយកូនៗ លុះកូនប្រុសមានវ័យបាន២០ឆ្នាំ ថៅមាណពជាឪពុកក៏ស្លាប់ទៅ។ កូនប្រុសនោះមិនដឹងរកស៊ីអ្វី ក៏នៅតែបន្តប្រកបរបររកត្រីសម្រាប់យកទៅចិញ្ចឹមម្ដាយ មិនឲ្យម្ដាយទៅណាឬធ្វើអ្វីទេ ឲ្យនៅតែផ្ទះៗ ឆ្នាំនេះដល់ខែផល្គុនថ្ងៃពេញបោរ ប្រជាជននិងពុទ្ធបរិស័ទដឹងថាជាថ្ងៃសីល ទើបម្នាក់ៗអត់ទៅរកត្រី អត់សម្លាប់សត្វទេៗ ឯថៅមាណពវិញមិនដឹងថាជាថ្ងៃពេញបោរខែដាច់ហើយក៏មិនដឹងថាជាថ្ងៃអ្វីដែរ គាត់ដឹងត្រឹមតែថាជារៀងរាល់ថ្ងៃត្រូវចេញទៅរកត្រីឲ្យបានដើម្បីយកទៅដោះដូរអង្ករយកទៅចិញ្ចឹមម្ដាយ ទើបថ្ងៃនោះគាត់ក៏ចេញទៅរកត្រីជាធម្មតាៗ ពេលទៅដល់ ថៅមាណពឆ្ងល់ថា៖ "អេប្លែក ចុះគ្មាននរណាមកត្រីរកសាច់អីទេឬ?"

មិនឃើញមានមនុស្ស ថៅមាណពក៏មិនខ្វល់ដែរគិតតែរកត្រីតែម្នាក់ឯងទៅៗ ហេតុនេះហើយទើបធ្វើឲ្យព្រះឥន្ទ្រក្ដៅក្រហាយណាស់ៗ ព្រះឥន្ទ្រឆ្ងល់ថា៖ "អេ! ថ្ងៃនេះម៉េចដូចជាក្ដៅក្រហាយណាស់នៅមិនបានដូច្នេះ? ដល់ក្បាលព្រលប់ ព្រះឥន្ទ្រក៏បើកទិព្វចក្ខុមើលមកឋានកណ្ដាលហើយលាន់មាត់ថា៖ "អូ! ថៅមាណពរុតត្រីថ្ងៃសីលតើ!"

យល់ថាជាថ្ងៃសីល មិនអាចបង្អង់យូរបាន ព្រះឥន្ទ្រក៏កាឡាខ្លួនជាតាចាស់កាន់ឈើច្រត់ ដើរចូលមកសួរថៅមាណព៖ "ថៅអើយ! ថៅឯងរកត្រីបានឬមិនបាន?"

ថៅមាណពតប៖ "លោកតាអើយ! ខ្ញុំរកបានមួយលោកតា!"

តាចាស់ថា៖ "អើ មើលតាសុំហូបបានឬមិនបាន?"

ថៅមាណពថា៖ "មានអីលោកតា បើលោកតាចង់ហូប ចាំខ្ញុំដុតឲ្យពិសា!"

តាចាស់ត្អូញថា៖ "អើ តាវង្វេងផ្លូវពីរបីថ្ងៃទៅហើយ រកផ្ទះរកសំបែងអត់ឃើញទេ!"

ចៅមាណពអាណិតហើយថា៖ "តាអត់បាយបីថ្ងៃទៅហើយ! បើអញ្ចឹងមិនអីទេតា ចាំខ្ញុំដុតត្រីឲ្យពិសា!"

ចៅមាណពក៏ឡើងយកត្រីមកដុតឲ្យតាពិសា។ ដល់ពិសារួចហើយ តាចាស់ក៏សួរថា៖ "អឺ ចៅឯង!ម៉េចមករកត្រីតែឯងអញ្ចឹង? តាមសព្វដងគេមករកច្រើនៗគ្នា ក៏ប៉ុន្តែថ្ងៃនេះម៉េចបានជាគេមិនមក ចៅឯងមិនដឹងទេអី?"

"ខ្ញុំអត់ដឹងថាថ្ងៃអីថ្ងៃអីទេលោកតា ខ្ញុំមិនដឹងទេ!" មាណពតប។

តាចាស់សួរបន្ត៖ "ចុះសព្វថ្ងៃនេះចៅឯងរកត្រីបានមក តើយកទៅណា?"

ចៅមាពណរាយរ៉ាប់ប្រាប់តាថា៖ "ខ្ញុំអត់មានយកទៅណាទេ គឺយកទៅចិញ្ចឹមម្ដាយ! ម្ដាយខ្ញុំចាស់ហើយ ឯឪពុកខ្ញុំក៏ស្លាប់បាត់ទៅទៀត! ខ្ញុំមិនដឹងរកស៊ីអីក៏រកតែត្រីមួយមុខ ព្រោះស្រែក្ដីគោក្របីក៏អត់មាន!"

តាចាស់សួរ៖ "ចុះបើចៅឯងបានស្រែបានក្ដីអី ចៅឯងចង់ធ្វើដែរឬមួយនៅតែរកត្រីទៀត?"

មាណពត្អូញថា៖ "ហ៊ឺ! បើខ្ញុំមានស្រែ ខ្ញុំមិនរកត្រីទេលោកតា! រកត្រីជួនណាបាន ជួនណាមិនបាន ជួនណាខ្សត់ផង បើមានស្រែខ្ញុំមិនរកទេត្រី របររកត្រីរកមិនបានទេ របស់នៅក្នុងទឹករកមិនងាយបានទេ!"

តាចាស់សួរ៖ "បើអញ្ចឹងចៅឯងដឹងថាថ្ងៃនេះជាថ្ងៃអីទេ? ថ្ងៃនេះ គឺជាថ្ងៃសីលពេញបោរខែផល្គុន គេមិនដែលរកត្រីទេ!"

មាណពឆ្លើយទាំងមិនដឹងថា៖ "ខ្ញុំអត់ដឹងទេលោកតា!"

តាចាស់ថា៖ "បើអញ្ចឹងចៅឯង ចាប់ពីថ្ងៃនេះឈប់រកត្រីទៅ!"

មាពណាថា៖" បើខ្ញុំឈប់រកត្រី តើខ្ញុំបានស្អីចិញ្ចឹមជីវិត ចិញ្ចឹមម្ដាយទៅ?"

តាចាស់ប្រាប់ថា៖ "មិនអីទេ! ចាំតាឲ្យមាសចៅឯង។ ចៅឯងយកមាសប៉ុនដូងទុំនេះទៅ តែត្រូវយកទៅឲ្យម្ដាយ ហើយឲ្យម្ដាយយកទៅឲ្យមហាសេដ្ឋីសុំដូរស្រែ សុំដូរគោក្របី សុំផ្ទះគេមក! បើគេឲ្យប៉ុណ្ណាយើងយកប៉ុណ្ណឹងមក កុំលោភ!"

ឲ្យមាសនិងផ្ដាំផ្ញើរួចហើយ តាចាស់ក៏រលាយខ្លួនបាត់ទៅ។ លុះតាចាស់ទៅបាត់ បុរសនោះឆ្ងល់ ហើយគិតថា៖"តើតាអំបាញ់មិញនេះ ម៉េចក៏ទៅណាបាត់ទៅ? អញ្ចឹងអញត្រូវយកមាសទៅឲ្យម្ដាយអញ!"

ដល់យកមាសទៅឲ្យម្ដាយ។ ម្ដាយសួរថា៖" ចុះឯងយកមាសមកពីណា?"

មាណពប្រាប់ម្ដាយថា៖ "តាម្នាក់គាត់ឲ្យខ្ញុំឈប់រកត្រីទៅ ព្រោះថ្ងៃហ្នឹងថ្ងៃសីល កុំឲ្យខ្ញុំរកត្រី គាត់ក៏ឲ្យមាសមកខ្ញុំ ឲ្យខ្ញុំយកមាសមកឲ្យម៉ែឯង ហើយឲ្យម៉ែឯងយកទៅឲ្យមហាសេដ្ឋីសុំផ្ទះ សុំគោក្របី មហាសេដ្ឋីឲ្យប៉ុណ្ណាយើងយកប៉ុណ្ណឹងទៅ គាត់ផ្ដាំផ្ញើអញ្ចឹង!"

អរណាស់ ម្ដាយចៅមាណាព ក៏យកមាសទៅផ្ទះមហាសេដ្ឋី។

មហាសេដ្ឋីលាន់មាត់ថា៖ "យី! ឯងលួចគេដឹង?"

ម្ដាយមាណពថា៖ "អត់មានលួចទេ! កូនខ្ញុំទៅរុតត្រីថ្ងៃមិញ តាហ្នឹងគាត់យកមាសមកឲ្យថាឈប់រុតត្រីទៅ ក៏ឲ្យមាសប៉ុនដូងទុំយកមកឲ្យលោកមហាសេដ្ឋី ហើយសុំដូយកស្រែនិងផ្ទះមក បើលោកមហាសេដ្ឋីឲ្យប៉ុណ្ណា ខ្ញុំយកប៉ុណ្ណឹង គ្រាន់តែមាសនោះគាត់ផ្ដាំផ្ញើមកឲ្យមហាសេដ្ឋីដូច្នេះឯង។"

ស្ដាប់ហើយមហាសេដ្ឋីក៏ថា៖ "អូ! បើអញ្ចឹងមិនអីទេ យើងឲ្យបាវព្រាវទៅធ្វើផ្ទះឲ្យមួយចែកកូនចែកចៅ

ចែកស្រែខ្ញុំបម្រើប្អូនប្រាំនាក់ទៅទៀតចុះ!"

នាងជាម្ដាយក៏ត្រលប់មកផ្ទះវិញ។ ចាប់ពីពេលនោះមក គ្រួសារនេះក៏មានជីវភាពធូរធារ។

និយាយពីតាជីយាយជីនោះវិញ គាត់ជាអ្នកកាន់សីលឧបោសថអត់បាយល្ងាច។ លុះទៅឃើញបុរសនោះមានជីវភាពដូច្នេះធ្ងល់ថា៖ "ចុះអានេះអត់រកស៊ីអីធំដុំសោះ! ម៉េចក៏មហាសេដ្ឋីមកជួយធ្វើផ្ទះធ្វើអីឲ្យ ឲ្យទាំងខ្ញុំបម្រើ ចែកគោចែកក្របីឲ្យដូច្នេះ? "

មិនអស់ចិត្ត ក៏នាំគ្នាទៅសួរថៅមាណពទៀតថា៖ "អើ ថៅមាណពឯង ម៉េចបានជាទៅត្រូវគ្នានឹងមហាសេដ្ឋី បានជាសេដ្ឋីចែកគោចែកក្របីឲ្យថៅឯងដូច្នេះ?"

ថៅមាណពនោះប្រាប់ថា៖ "អើ លោកយាយលោកតាអើយ ម្សិលមិញជាថ្ងៃពេញបោរមីខែផល្គុនខ្ញុំទៅវត្តត្រីតែឯងគ្មាននរណាទៅវត្តទេ ខ្ញុំឃើញតាចាស់ហ្នឹងគាត់កាន់ឈើច្រត់មក គាត់វង្វេងផ្លូវបីថ្ងៃហើយអត់បាយផង។ គាត់សុំត្រីខ្ញុំ ខ្ញុំក៏ដុតឲ្យគាត់ពិសារ។ តាចាស់សួរថា៖ "ឯងមិនដឹងទេថ្ងៃនេះថ្ងៃអី!" ហើយខ្ញុំប្រាប់គាត់វិញថា៖ "អត់ដឹងទេ មិនដឹងថាថ្ងៃនេះថ្ងៃអីទេ មិនដឹងថាថ្ងៃ៨ពេញបោរមីខែដាច់អី ខ្ញុំអត់ដឹងទេ!"

គាត់ប្រាប់ថា៖ "ថ្ងៃនេះជាថ្ងៃសីល ឈប់ទៅរកត្រីទៅ។ រួចគាត់បានឲ្យមាសប៉ុនដូងទុំមកឲ្យខ្ញុំ ឲ្យខ្ញុំយកទៅជូនលោកមហាសេដ្ឋី សុំចែកគោក្របី បើគាត់ឲ្យប៉ុណ្ណាយកប៉ុណ្ណឹងទៅ!"

យាយតាឧបោសថបានស្ដាប់ហើយក៏គិតថា៖ "ឯងកាន់សីលយូរណាស់ហើយមិនបានមហាសេដ្ឋីគិតផ្ទះគិតសំបែងអីឲ្យសោះ។ បើអញ្ចឹងឆ្នាំក្រោយ បើថ្ងៃពេញបោរមីខែផល្គុនមកដល់ យើងនឹងបបួលគ្នាទៅវត្តត្រីម្ដង!"

លុះឆ្នាំក្រោយ ថ្ងៃពេញបោរខែផល្គុនមកដល់ បន្ទាប់ពីកាន់សីលរួច តាជីយាយជីទាំងអស់ក៏ណាត់គ្នាទៅរកត្រីនៅបឹងមែនៗ យាយៗនាំគ្នាកាន់កញ្ច្រែងទៅ ឯតាៗកាន់អង្រុតនិងសំណាញ់ៗ យាយៗនាំគ្នាវំតែជញ្ជាត់ តាៗនាំគ្នាវំតែរុតនិងបង់ត្រីៗ ឆ្នាំនេះក៏ក្ដៅក្រហាយដល់ព្រះឥន្ទ្រទៅទៀតៗ

ព្រះឥន្ទ្រគិតថា៖ "អីក៏ក្ដៅ ក្រហាយអ្វីម្ល៉េះ?"

គិតហើយព្រះឥន្ទ្រក៏បើកព្រះនេត្រមកមើលឃើញមនុស្សហើយលាន់មាត់ថា៖ "អេយី! យាយជីតាជីគាត់មកលេងត្រីក្នុងបឹងអោយខូចតែម្ដងទេតើ! អូ មិនកើតទេ នៅមិនបានទៀតទេ អញទៅមើលសិន!"

ព្រះឥន្ទ្រក៏ក្លែងខ្លួនធ្វើជាតាចាស់ដូចឆ្នាំមុនដែរ ដើរជុំវិញបឹង រួចក៏ដើរសំដៅទៅតាយាយហើយនិយាយថា៖ "ម៉េចអី យាយតាបានត្រីអីទេ?"

តាជីយាយជីអត់ទាន់និយាយតបតាសោះ តែងាកមកខ្សិបខ្សៀវគ្នាថា៖ "តាហ្នឹងឯងឲ្យមាសថៅមាណពប៉ុនដូងទុំឆ្នាំទៅមិញ!"

អ្នកខ្លះខ្សិបថា៖ "បើអញ្ចឹងយើងទាំងអស់គ្នាសុំមាសម្ដុំៗម្នាក់ពីគាត់ទៅ!"

តាសួរពីរបីដងក៏តាជីយាយជីទាំងនោះនៅមិនទាន់និយាយតបៗ តាសួរម្ដងទៀតថា៖ "មើល ឡើងមកមើល ម៉េចបានត្រីទេ?"

តាជីយាយជីព្រមតបហើយក៏ឡើងមក ខ្លះថាបាន ខ្លះថាមិនបានៗ

ខ្លះសួរតាវិញថា៖ "លោកតាហ្នឹងឬដែលឆ្នាំទៅមិញឲ្យមាសថៅមាណពនោះ?"

តាតបថា៖ "អើយើងហ្នឹងហើយ?"

តាជីយាយជីក៏នាំគ្នាសុំ៖ "អញ្ចឹងយើងទាំងអស់គ្នាសុំមាសម្ដុំៗម្នាក់មក!"

"មិនអីទេ! ចុះតាជីយាយជីដឹងទេថាថ្ងៃនេះជាថ្ងៃអីទេ?" តាសួរ។

យាយជីតាជីតប៖ "ថីមិនដឹងថ្ងៃនេះថ្ងៃសីល ខ្ញុំទទួលសីលឧបោសថហើយទើបខ្ញុំមករុតត្រី! ព្រោះចង់បានមាសដូចថៅមាណពដែរ!"

តាតប៖ "យាយជីតាជីឯងដឹងថ្ងៃពេញបោរខែដាច់ហើយនៅតែមកធ្វើបំពានលើហ្នឹងទៀត បើធ្វើអញ្ចឹងអត់កើតទេ! ថៅមាណពគ្នាមិនដឹងថ្ងៃ៨ពេញបោរខែដាច់ជាថ្ងៃអ្វីទេ គ្នាអត់ដឹងវាមិនជាអីទេ! តែតាយាយឯងនេះក្នុងជីវិតរបស់យាយឯងតាឯងដឹងហើយនៅតែមកបំពានទៀត បើអញ្ចឹងកើតជាសត្វស្វាទាំងអស់គ្នាទៅ!"

តាជី យាយជីទាំងនោះក៏កើតទៅជាសត្វស្វារហូតដល់សព្វថ្ងៃ។

មើលពិចារណាមើលទៅរឿងនេះ។ ខ្ញុំក៏ចេះពីគេដែរ ខ្ញុំអត់មានចេះខ្លួនឯងទេ។ ខ្ញុំចេះពីគ្រូមហាពេជ្រនៅវត្តដំរីស ខេត្តបាត់ដំបងនិងគ្រូម្ចាស់សាននៅវត្តកំផែង ។ ឥឡូវគាត់ស្លាប់អស់ហើយ ហើយបើគាត់កខ្ញុំករដែរកតៗគ្នា៕

# ៨- រឿងហេតុអ្វីបានជាសត្វស្វាមានមុខដូចមនុស្ស ?

**និទានដោយតា រឹម** [10]

មានរឿងតំណាលថា កាលនោះស្ដេចព្រហ្មទត្តបានលើកបុត្រីឲ្យទៅបុរសម្នាក់។ ក្រោយមកមិនដឹងបុរសនោះមានកំហុសអ្វី ម្ដាយក្មេកឪពុកក្មេកខឹងខ្លាំងណាស់ ក៏យកបុរសនេះទៅវាយចោលក្រោមដើមជ្រៃមួយរហូតសន្លប់បាត់មាត់ឈឹង។ ស្មានតែបុរសនោះស្លាប់ហើយ ព្រះរាជាក៏ត្រលប់ទៅវិញ។ នៅក្រោមដើមជ្រៃ បុរសនោះដឹងខ្លួនឡើងហើយបើកភ្នែកសម្លឹងមើលទៅផ្លែជ្រៃទាំងបីដើមនោះ។ អ្នកថែរក្សាដើមជ្រៃនោះមានចិត្តអាណិតក៏បន្លឺសម្លេងជាអ្វីមួយ ឮខ្សាវៗថា៖ "ដើមជ្រៃនេះ បើស៊ីផ្លែវាទៅនឹងអាចក្លាយជាសត្វផងមនុស្សផង។"

ដោយឃ្លានពេក បុរសនោះក៏បេះផ្លែជ្រៃនោះមកបរិភោគ។ បន្ទាប់ពីស៊ីផ្លែជ្រៃដើមទីមួយរួច បុរសនោះស្រាប់តែក្លាយខ្លួនជាកុក ដូច្នេះភ័យណាស់ក៏ស៊ីផ្លែជ្រៃដើមទីពីរទៀត ស្រាប់តែបុរសនោះកើតទៅជាសត្វស្វា។ កើតជាស្វាដូច្នេះ ភ័យណាស់ក៏ឆាកទៅ ស៊ីផ្លែជ្រៃនៅដើមទីបីទៀត ទើបក្លាយជាមនុស្សដែលមានសម្រស់ស្រស់ស្អាតនិងវ័យក្មេងវិញ។

បុរសនោះបានដឹងមហិទ្ធិរិទ្ធិដើមជ្រៃនេះហើយ ត្រេកអរណាស់ ដោយមានចិត្តខឹងនឹងឪពុកម្ដាយក្មេកដែលដាច់ចិត្តសម្លាប់ខ្លួនក៏រើសផ្លែជ្រៃនោះបានមួយបង្វិចមក។ ខឹងពេកណាស់ បុរសនោះក៏ត្រលប់ទៅរកឪពុក

---

10 ភូមិអូររំចេក ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់។

ម្ដាយក្មេកវិញដើម្បីសងសឹក។ ពេលត្រលប់មកដល់ផ្ទះវិញ ឪពុកម្ដាយក្មេកនិងកវិយាមានការភ្ញាក់ផ្អើលជាខ្លាំង ហើយក៏កាន់តែមានកំហឹងខ្លាំងថែមទៀត នៅពេលដែលសម្លាប់បុរសនេះហើយមិនស្លាប់ បែរជាត្រលប់មកវិញថែមទាំងមានសម្រស់ស្រស់ស្អាតក្មេងជាងវ័យទៀតផង។

បន្ទាប់មក ស្ដេចព្រហ្មទត្តក៏សួរទៅបុរសនោះថា៖ "អញស្អប់អាឯងណាស់! អញសម្លាប់អាឯងប៉ុន្មានដងហើយ ឥឡូវម្ដេចអាឯងអាចមកវិញបានហើយបែរទៅជាក្មេងដូច្នេះ? អាឯងបានអ្វីស៊ីបានថ្នាំអ្វីបានជាក្មេងដូច្នេះ?"

បុរសនោះនិយាយថា៖ "ខ្ញុំមិនអាចប្រាប់ថ្នាំនេះបានទេ! ឥឡូវឪឯងចង់បានខ្លួនក្មេង ឪទៅហៅក្រុមគ្រួសារម៉ាថៅកេតជីដូនជីទួតលួតលាឪឯងមក ចាំខ្ញុំប្រាប់ឲ្យថ្នាំលេបនឹងក្លាយជាក្មេងទាំងអស់គ្នា។"

ស្ដេចក៏បង្គាប់ឲ្យហៅញាតិសន្ដានមក។ ជួបជុំគ្នាហើយ បុរសនោះក៏យកផ្លែជ្រៃចែកឲ្យម្នាក់មួយគ្រាប់ៗ ហើយប្រាប់ថា៖ "ចាំខ្ញុំរាប់មួយពីរបីហើយចាំលេប!"

បុរសនោះសួរបញ្ជាក់ជាចុងក្រោយម្ដងទៀត៖ "តើមកជុំគ្នាហើយឬនៅ?

"រួចហើយ!" ស្ដេចនិងញាតិសន្ដានទាំងអស់គ្នាតប។

"បើរួចហើយមួយពីរបីលេប!" បុរសនោះរាប់ខ្លាំងៗ។

គ្រាន់តែឮថាលេប ទាំងស្ដេចទាំងញាតិទាំងអស់ក៏នាំគ្នាលេបព្រមគ្នា។ គ្រាន់តែលេបគ្រាប់ជ្រៃគ្រឹបចូលក្នុងពោះភ្លាម មួយថៅកេតស្ដេចក៏ក្លាយជាស្វាទាំងអស់គ្នាមួយរំពេច។ ឯបុរសនេះក៏ទាញដំបងដេញវាយស្វាទាំងនោះឲ្យរត់ចូលទៅរស់នៅក្នុងព្រៃអស់ទៅ!។

ចំណែកប្រពន្ធបុរសនេះមិនទាន់លេបភ្លាមៗទេ។ បុរសនោះឃើញប្រពន្ធមិនទាន់លេបក៏និយាយឡើងថា៖ "អញលែងឲ្យជួបហើយ ព្រោះអញបានធ្វើបាបគេច្រើនណាស់!"

ថារួចគាត់ក៏បង្ខំឲ្យនាងជាប្រពន្ធលេបគ្រាប់ជ្រៃនោះរហូតកើតទៅជាស្វាដែរ ឯខ្លួនគាត់ក៏បានយកផ្លែជ្រៃមួយគ្រាប់មកលេបក្លាយជាសត្វកុកហើរទៅចេញពីនាងទៅ។ ទៅដល់កន្លែងមួយស្ងាត់ គាត់ក៏លេបផ្លែជ្រៃឲ្យកើតជាមនុស្សវិញហើយរស់នៅតែម្នាក់ឯងទៅ។ ហេតុដូច្នេះហើយបានជាស្វាមានមុខមាត់ដូចមនុស្សដែរ។

# ៩- រឿងសត្វមូស

## និទានដោយ ស្រីលក្ខណ៍ [11]

*កាលពីជំនាន់ដើម មូសហ្នឹងធំណាស់។ នៅថ្ងៃមួយមូសមកស៊ីមនុស្សនៅតាមភូមិ។ ក្នុងភូមិហ្នឹងមានមនុស្សជាច្រើនស្លាប់ដោយសារមូសស៊ី។ ថ្ងៃមួយសេដ្ឋីហ្នឹងក៏ប្រាប់ឲ្យចាត់ទាហានចាប់អ្នកស្រុកអ្នកភូមិយកមកឲ្យមូសស៊ី។ សេដ្ឋីធ្វើបាបគេម្នាក់ម្ដងៗ ហើយអ្នកស្រុកក៏ព្រួយសោកបោកខ្លួនព្រោះអីខ្លាចមូសនោះស៊ី។*

*ឃើញដូច្នេះ កូនក្រមុំសេដ្ឋីហ្នឹងក៏ទៅសុំសេដ្ឋីជាឪពុកខ្លួនឯងថា៖ "ពុកៗ បើបណ្ដោយឲ្យមូសនោះស៊ីអ្នកស្រុករាល់ថ្ងៃអញ្ចឹង អ្នកភូមិយើងនឹងស្លាប់អស់គ្មានសល់ទេ! ទើបនាងសុំប្រកាសឲ្យមូសស៊ីខ្លួនឯងម្ដង។ សេដ្ឋីហ្នឹងមិនឲ្យនាងទៅទេ តែនាងនៅតែចចេសទៅ ទើបសេដ្ឋីហ្នឹងឲ្យនាងទៅ។ ពេលនាងទៅអញ្ចឹង នាងប្រាប់អ្នកស្រុកអ្នកភូមិឲ្យដើររកកំទេចឬស្លឹកឈើ អុសឲ្យយកមកដុត កុំឲ្យមូសចូល ស្រាប់តែដុតឆេះជាផ្សែងហើយ មូសរកចូលក៏អត់កើត មូសនោះក៏ទៅសុំព្រះឥសូរ។*

*មូសសុំព្រះឥសូរថា៖ "ព្រះឥសូរ! ខ្ញុំសុំខ្លួនឲ្យនៅតូចវិញ!"*

*ព្រះឥសូរក៏ធ្វើតាម ហើយមូសក៏ត្រលប់ទៅខាំមនុស្សវិញ។ ពេលខាំមនុស្ស មាត់វាតូចខ្លីពេក ពេលវាខាំមិនទាន់បានមួយសន្ទុះផង មនុស្សក៏វាយវាងាប់ទៅ។*

*អញ្ចឹងមូសទាំងនោះក៏បបួលគ្នាមកសុំព្រះឥសូរម្ដងទៀតថា៖ "ព្រះឥសូរ ខ្ញុំចង់សុំឲ្យមាត់ខ្ញុំវែងអាចបឺត*

---

11 *វត្តបន្ទាយត្រាវ ភូមិត្រពាំងជ្រៃ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ*

ឈ្លាមមនុស្សបានលឿន!"

ព្រះឥសូរក៏ឲ្យមាត់វាវែងៗ មូសក៏ត្រលប់ទៅបឺតឈាមមនុស្សបន្តិចម្តងៗ ហើយទើបមនុស្សវាយវាបានៗ ចាប់ពីពេលនោះមក អ្នកស្រុកអ្នកភូមិលែងខ្លាចមូសស៊ីទៀតហើយ ព្រោះអីមូសក្លាយខ្លួនជាតូចវិញៗ ហើយពេលមនុស្សដេកតែងចងមុង ពេលមូសចូលក្នុងមុង វាត្រូវគេវាយងាប់ស្ទើតែផុតពូជៗ រឿងហ្នឹងចប់ប៉ុណ្ណេះឯងៗ៕

# ១០- រឿងកូនប្រសារពស់

## និទានដោយ ស្រីលក្ខណ៍ [12]

មានប្តីប្រពន្ធពីរនាក់មានជីវភាពសមរម្យ ប្រពន្ធមានផ្ទៃពោះៗ ជាធម្មតាអ្នកស្រុកចាស់នៅភូមិនោះមានជំនឿទៅលើកន្ទែងអ្នកតាដើមពោធិ៍ៗ អញ្ចឹងស្អែកឡើង នាងជាប្រពន្ធដែលជិតគ្រប់ខែនោះក៏ទៅបន់ព្រះបន់ទេវតានៅក្បែរដើមពោធិ៍នោះ បន់ហើយក៏ត្រលប់មកផ្ទះវិញៗ

លុះថ្ងៃបន្ទាប់មក នាងពោះធំនោះឈឺពោះកើតកូនៗ នៅថ្ងៃសំរាលកូននោះ ប្តីនាងនោះរវល់ណាស់រវល់ដាំទឹកដាំអីឲ្យប្រពន្ធៗ នាងនោះក៏កើតមកបានកូនស្រីមួយៗ ឮថាកើតបានដូចនោះ បុរសជាប្តីក៏សួរថា៖ "កូនហ្នឹងកើតមកស្រីឬប្រុស?"

យាយហ្មបហ្នឹងឆ្លើយថា៖ "បានកូនស្រីមួយ!"

ពីរនាក់ប្តីប្រពន្ធនោះអរណាស់ក្រោយពីដឹងថាបានកូនស្រីៗ ដល់កូននោះធំអាយុបាន៥-៦ឆ្នាំ ម៉ែប្រើកូននោះឲ្យពុះអុសទុកមួយកន្ទែងៗ

ប្តីហ្នឹងមកវិញសួរប្រពន្ធថា៖ "នែអូន! ស្អែកហ្នឹងទៅបន់អ្នកតាដើមពោធិទេ?"

ប្រពន្ធហ្នឹងក៏ឆ្លើយថា៖ "ចាស៎ ទៅ!"

កូនហ្នឹងសុំម៉ែថា៖ "ម៉ែៗ! កូនសុំទៅកន្ទែងអ្នកតាដើមពោធិដែរៗ"

---

12 វត្តបន្ទាយត្រាវ ភូមិត្រពាំងជ្រៃ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ

ម៉ែចេះតែជំទាស់ជាមួយកូន ហើយកូនចេះតែទទូចសុំម៉ែហ្នឹងទៅៗ សុំយូរទៅៗ ម៉ែហ្នឹងក៏ព្រមឲ្យកូនទៅៗ ហើយម៉ែនោះប្រាប់ឲ្យកូនហ្នឹងទៅរៀបចំឥវ៉ាន់ ស្លៀកពាក់ពាក់ឲ្យស្អាតៗ ហើយក៏នាំគ្នាជិះរទេះគោទៅកន្លែងដើមពោធិ៍នោះៗ មានមនុស្សជាច្រើនមកបន់នៅកន្លែងអ្នកតាដើមពោធិ៍នោះដើម្បីសុំសេចក្ដីសុខៗ ពេលពីរនាក់ប្ដីប្រពន្ធនិងកូនបន់សុំឲ្យមានសេចក្ដីសុខរួចហើយ ក៏ត្រលប់ទៅផ្ទះវិញៗ

ដល់ពេលនាងនោះពេញក្រមុំ ម៉ែឪនាងនោះក៏ចាស់ដែរៗ ចាស់នៅក្នុងភូមិនោះក៏បបួលនាងនោះថា៖ "នាងអើយ! ទៅបន់អ្នកតាដើមពោធិទេ?"

នាងនោះថា៖ "ទៅៗ"

នាងកូនស្រីប្រាប់ម៉ែនាងថា៖ "ម៉ែមិនបាច់ទៅទេ ទុកឲ្យកូនទៅវិញ!"

អញ្ចឹងម៉ែក៏ថា៖ "កូនទៅក៏ទៅចុះ ហើយយកអីទៅថ្វាយក៏ថ្វាយទៅ!"

ពេលនាងទៅដល់កន្លែងដើមពោធិនោះ កូនទេវតាក៏ចុះមកទតនៅកន្លែងនោះ ទតមើលចុះមើលឡើងក៏ស្រាប់តែឃើញស្រីក្រមុំកូនយាយនោះ ហើយក៏ចាប់ចិត្តស្រលាញ់ៗ នាងនោះក៏ចាប់បន់ស្រន់សុំឲ្យម៉ែរបស់នាងរស់នៅបានសេចក្ដីសុខ ហើយនាងក៏ត្រលប់មកផ្ទះវិញ ឯកូនទេវតាហ្នឹងក៏ឡើងទៅឋានសួគ៌វិញប្រាប់បិតាថា៖ "បិតាៗ! កូនដូចជាមាននិស្ស័យជាមួយកូនតាយាយនៅកន្លែងភូមិមួយៗ"

បិតាស្រាប់តែថា៖ "ព្រោះអីនាងជាគូនិស្ស័យជាមួយបុត្រាពីអតីតកាល ហើយបិតាហ្នឹងជាអ្នកបើកទិព្វឲ្យបុត្រាមើលឃើញៗ"

កូនទេវតាក៏សួរបិតាថា៖ "បុត្រអាចចាប់ជាតិទេពច្យុតចុះនៅឋានក្រោមបានទេ?"

បិតាក៏ឆ្លើយថា៖ "ចុះមិនបានទេ ព្រោះអីយើងចាប់ជាតិមិនទាន់គេ។ ឥឡូវគេធំពេញវ័យហើយ ហើយកូននៅឋានសួគ៌ក៏ធំពេញវ័យដែរ។ បើចុះទៅឋានក្រោមទេពច្យុតកូនទើបតែកើត ឯគេនោះធំពេញវ័យហើយ អញ្ចឹងស្រលាញ់គ្នាជាគូម៉េចនឹងបាន? បុត្រចាប់ជាតិក៏មិនទាន់គេទេ។ ថាហើយបិតានោះក៏យកកែវទិព្វឲ្យបុត្រខ្លួនឯងមើល។"

បុត្រនោះមើលហើយក៏ឃើញពីអតីតកាល គេនឹកឃើញដល់យប់មួយ គេក្លែងបន្លំធ្វើជាពស់ថ្លាន់មួយចូលក្នុងបន្ទប់នាងនោះ។ នាងហ្នឹងក៏ស្រែកហៅម្ដាយនាងថា៖ "ម៉ែៗ! ពស់ៗ!"

ពស់នោះក៏ឆ្លើយតបថា៖ "កុំខ្លាចខ្ញុំអី! ខ្ញុំមិនមែនជាពស់ទេ ខ្ញុំជាទេវតា។"

ពស់ហ្នឹងក៏ប្រែកាឡាជាទេវតា នាងឃើញដូច្នេះក៏ឈប់ខ្លាច។ ពេលយប់មួយទៀត ពស់ថ្លាន់ហ្នឹងមកម្ដងទៀត នាងក្រមុំនិងពស់ថ្លាន់និយាយគ្នាមួយសន្ទុះ។ ម្ដាយឮក៏នឹកឆ្ងល់ថាកូនស្រីខ្លួននិយាយជាមួយនរណាគេ ហើយក៏លបទៅមើលឃើញពស់ថ្លាន់នៅជាមួយកូន។ ព្រឹកឡើងសួរកូនថា៖ "កូន!ម៉េចកូនឯងនិយាយជាមួយពស់ថ្លាន់អញ្ចឹង?

កូនហ្នឹងក៏រៀបរាប់ថា៖ "គាត់មិនមែនជាពស់ថ្លាន់ទេ គាត់ជាទេវតាចុះមកពីឋានលើ។"

ពេលយប់មកដល់មិនឃើញពស់នោះមក នាងនោះនិយាយម្នាក់ឯងថា៖ "ម៉េចក៏បងពស់ថ្លាន់មិនទាន់មកទៀត?"

ពស់ថ្លាន់ឮក៏វារមក ហើយក៏និយាយគ្នា។ ឪពុកម្ដាយហ្នឹងឮ ក៏នាំចេញមកនិយាយថា៖ "កូនប្រសារពស់កុំខ្លាចអី! ប្រែកាឡាជាមនុស្សមក ហើយពស់ហ្នឹងក៏ហ៊ានប្រែកាឡា។"

ម្ដាយឪពុកហ្នឹងនិយាយថា៖ "អញ្ចឹងចាប់រៀបការថ្ងៃស្អែកចុះ បើកូនទាំងពីរស្រលាញ់គ្នាហើយៗ" មិនទាន់ការទេ ស្រាប់តែពស់ថ្លាន់ហ្នឹងទៅបាត់ៗ

មានយប់មួយពេលកូននោះកំពុងតែដេកលង់លក់ ពស់ថ្លាន់មកពន្យល់សប្ដិឲ្យនាងហ្នឹងទៅកាយកំណប់នៅក្នុងព្រៃ ឲ្យតែកន្លែងណាមានពំនូក កន្លែងនោះហើយមានកំណប់ៗ នាងនោះក៏ទៅ នាងប្រាប់ម្ដាយនាងឲ្យជិះរទេះគោទៅកន្លែងកំណប់នោះៗ ពេលទៅដល់ព្រៃនោះ ឪពុកនាងឃើញទួលមួយ ហើយប្រាប់ទៅប្រពន្ធខ្លួនថា៖ "ប្រហែលជាពំនូកនេះដែលពស់ថ្លាន់នោះបានប្រាប់យើងៗ"

ម្ដាយរបស់នាងហ្នឹងក៏ឲ្យប្ដីរបស់ខ្លួនទៅហូបបាយឲ្យឆ្អែតសិន រួចសឹមទៅកាប់គាស់ពំនូកដីនោះៗ ពេលកាប់ទៅ ឃើញសុទ្ធតែមាសកែវកង ហើយក៏នាំគ្នាយកមាសកែវកងទាំងនោះត្រលប់មកផ្ទះវិញ ទុកចាំស្អែកចាំចែកឲ្យអ្នកស្រុកអ្នកភូមិម្នាក់បន្ដិចៗ ។ យប់នោះគេនឹងរៀបចំរៀបការនាងក្រមុំជាមួយនឹងពស់ថ្លាន់ ហើយនឹងចែកសារុងក្រមាសូត្រដល់អ្នកស្រុកម្នាក់មួយៗៗ

ពេលយប់នោះ កូនក្រមុំនោះថា៖ "បងមានឃ្លានអីទេ? ចាំខ្ញុំទៅយកឲ្យៗ"

ពស់ហ្នឹងឆ្លើយថា៖ "ឃ្លានៗ"

នាងក៏ទៅយកចំណីឲ្យពស់ថ្លាន់ហូបទៅៗ

និយាយពីនាងម្នាក់ទៀតនៅក្នុងភូមិនោះដែរ ឃើញនាងនោះរៀបការជាមួយពស់ហើយបានមាសផងក៏ចង់បានដូចគេដែរៗ ពេលមកដល់ផ្ទះក៏រំអុកឲ្យម៉ែរកពស់ថ្លាន់មកការជាមួយដើម្បីបានមាសហ្នឹងគេដែរៗ ស្រាប់តែម៉ែនោះទៅដើររកពស់ថ្លាន់មែនទែនយកមកការជាមួយកូនខ្លួនឯងហើយថាសមគ្នាៗៗ ដល់ពេលយប់

នោះទៅផ្សំជុំណោកគិតនិយាយបងអូនចុះឡើងៗ ស្រាប់តែពស់នោះខាំលេបនាងនោះៗ

ពេលលេបនាងនោះដល់កជើង នាងស្រែកប្រាប់ម៉ែថា៖ "ម៉ែៗ! ត្រឹម កជើងហើយ!"

ម៉ែថា៖ "អឺ! មិនអីទេទ្រាំតិចទៀតទៅ!"

ដល់ម្ដងទៀត ពស់នោះលេបត្រឹមភ្លៅ នាងនោះស្រែកថា៖ "ម៉ែៗត្រឹមភ្លៅហើយ!"

ម៉ែថា៖ "អឺ! វាមិនអីទេ! ប្ដីធ្វើលេងសោះហ្នឹងណា!"

ដល់មួយសន្ទុះទៅ ដល់ត្រឹមចង្កេះ ដល់ត្រឹមត្រគាកហើយនាងស្រែកប្រាប់ម៉ែៗ

ម៉ែថា៖ "អឺ! មិនអីទេប្ដីធ្វើលេងហ្នឹង!"

ដល់ម្ដងទៀត ដល់ត្រឹមពោះដល់ទ្រូងដល់ត្រឹម ក ហើយប្រាប់ម៉ែៗ

ម៉ែថា៖ "កូនទ្រាំតិចទៅកូន! ប្ដីធ្វើលេងប្ដីគ្រាន់តែប្រលែងជាមួយហ្នឹង!"

ស្រាប់តែដល់ត្រឹមក្បាលលិចក្បាលទៅ កូនហ្នឹងលែងស្រែកហើយៗ ម៉ែថា៖ "ចុមម៉េច! កូនខ្ញុំស្រែកម៉េចឥឡូវលែងស្រែកទៅហើយ?"

ដល់ធ្វល់អញ្ចឹងទៅ ស្រាប់តែម៉ែនោះទៅមើលកូន ឃើញកូនដៃខ្វៃៗឲ្យជួយ ហើយពស់ហ្នឹងលេបចូលនៅសល់តែដៃទេៗ ម្ដាយនាងនោះក៏ស្រែកហៅឲ្យគេជួយ ហើយក៏ចុះមកប្រាប់អ្នកស្រលាញ់កូនគាត់ពីមុនថា៖ "ពស់លេបកូនអញចូលក្នុងពោះហើយៗ"

ដល់ពេលដឹងហើយឪពុករបស់បុរសដែលស្រលាញ់នាងនោះ ក៏ស្រវេស្រវាយកកាំបិតទៅវះសត្វពស់នោះដើម្បីយកនាងជាកូនហ្នឹងចេញពីខ្លួនពស់ៗ លុះដល់វះហើយ មានឈាមពស់ប្រលាក់នាងនឹងឡើងពេញ

កូនហ្នឹងចេញបាន តែក្រោយមកជកជង្រើមបានតិចៗក៏យកនាងនោះទៅអាំងរងើកភ្លើងៗ អាំងភ្លើងហើយនាងនោះដឹងខ្លួនរស់ឡើងវិញៗ នាងនោះក៏ទៅងូតទឹកដុសក្អែលឲ្យអស់រអិលពស់តែអត់ជ្រះទេៗ ក្រោយមកទៀតនាងនោះខឹងនឹងខ្លួនឯងពេកក៏យកផ្ដិលគ្របក្បាលខ្លួនឯង ហើយលោតចុះទឹកសមុទ្រទៅៗ

ស្រាប់តែព្រលឹមឡើង ម៉ែក្រោកពីដេក ទៅមើលកូន តែរកមិនឃើញកូនៗ ពេលម៉ែនោះចុះងូតទឹកស្រាប់តែឃើញត្រីផ្សោតមួយ ម្ដាយហ្នឹងក៏ដើរសួរគេឯងថា៖ "ពូៗ បងៗមានឃើញត្រីផ្សោតទេ?"

ពូនោះឆ្លើយថា៖ "ឃើញតើ! នោះត្រីផ្សោត!"

ស្រាប់តែម្ដាយក្រឡេកទៅឃើញត្រីផ្សោតក៏យំ យំបោកខ្លួនព្រោះរូបផ្សោតជារូបកូនរបស់ខ្លួនៗ

ថ្ងៃងពីគ្រួសារដែលគេការជាមួយពស់កូនទេវតាហ្នឹង គេក៏រុងរឿងរហូត គេមិនដែលមានរឿងអីទេ អត់មានចង្រៃមានអីទេៗ ហើយរឿងនោះក៏ចប់ទៅ ៕

# ១១- រឿងប្រវត្តិពស់ថ្លាន់

## និទានដោយលោកតា អិន អៀន [13]

ពីដើមដីកុលហើយមនុស្សដើរអត់មានស្បែកជើងពាក់ទេ។ និយាយពីពស់ថ្លាន់ពីដើមខ្លាំងពូកែណាស់ ឃើញតែបាទជើងដានជើងយើងហ្នឹងលិទ្ធទៅឆាប់ដល់ម្ចាស់ខ្លួន។ ពស់ផ្សេងៗដូច្នេះ ក៏នឹកចង់រៀនមហិទ្ធិរិទ្ធពីពស់ថ្លាន់ ក៏គិតនាំគ្នាទៅថ្វាយបង្គំសម្ដេចព្រះគ្រូថ្លាន់ ហើយបម្រើទឹកក្ដៅទឹកត្រជាក់ ប្របាច់ជើងប្របាច់ដៃឲ្យគាត់ទាំងយប់ថ្ងៃ គិតក្រែងលោពស់ថ្លាន់មានឲ្យពិស មានឲ្យគាថាអីសម្រាប់យកមកការពារខ្លួនខ្លះ។

ដល់អញ្ចឹងទៅ មានអាពស់មួយទៅនៅបម្រើព្រះគ្រូពស់ថ្លាន់នោះ។ យូរទៅៗក៏និយាយថា៖ "លោកគ្រូអើយ! ខ្ញុំមកបម្រើលោកគ្រូរាប់ឆ្នាំរាប់ខែយូយារណាស់ហើយមិនទាន់បានអីបន្តិចបន្តួចផង ថែមទាំងឥឡូវនឹកដល់ផ្ទះសំបែងម៉ែឪខ្ញុំទៀត បើអញ្ចឹងខ្ញុំគិតសុំលាលោកគ្រូទៅវិញហើយ!"

លោកគ្រូជាពស់ថ្លាន់តបថា៖ "ហេ! ហ្អែងកុំអាលខឹងអញ ចូលមកជិតអញមក។"

អានោះដល់ចូលមកជិត ពស់ថ្លាន់ថា៖ "ហ្អែង! ហាមាត់ឡើង! ហាមាត់ឡើង!"

ថាហើយ ពស់ថ្លាន់ក៏ខ្ជាក់បានពិសមួយមេមកឲ្យទៅកូនសិស្សរបស់ខ្លួន។ បានពិសពីគ្រូពស់ថ្លាន់ខ្ជាក់ឲ្យហើយ កូនសិស្សនោះក៏ថ្វាយបង្គំលាព្រះគ្រូថ្លាន់មកស្រុកវិញ។

ពេលវិលមកស្រុកវិញ ពស់ឯទៀតៗឃើញដូច្នោះសរសើរថា៖ "យី! អានេះវាទៅបម្រើលោកគ្រូថ្លាន់

13 ភូមិសំបួរមាស១ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។

យូរណាស់ហើយក៏មានមហិទ្ធិរិទ្ធិខ្លាំងពូកែមែន ដាក់អានោះប៉ក់ប្រកាច់ ដាក់អានោះប៉ក់ប្រកាច់ៗ

អាមួយនោះថា៖ "អេ! បើអញ្ចឹងអញគិតទៅដែរ!"

អាមួយទៀតថា៖ " អញទៅដែរ!"

គិតហើយអាពស់មួយ ក៏ទៅរកព្រះគ្រូពស់ថ្លាន់ៗ ពេលពស់នោះទៅដល់ ក៏ផ្ដាប់ផ្គុនធ្វើដូចអ្នកមុនៗ ហើយថែមទាំងលេងភ្លេង បទអន្ទង មានបទអន្ទងខ្មោច អន្ទងចិត្ត ឡើងភ្នំចុះភ្នំ បទសុរិន្ទខ្នងភ្នំ ដាក់ស្នេហ៍បន្ទន់ចិត្តដល់ពស់ថ្លាន់ៗ ដល់អញ្ចឹងទៅ អាមួយទៅក្រោយក៏បានទៀតហើយលាមកវិញៗ ពស់មួយចេញ ពស់មួយទៀតចូល ពស់មួយចេញ ពស់មួយចូល! យូរៗទៅពស់ថ្លាន់ក៏ខ្លាក់ពិសឲ្យគេអស់រលីងៗៗ ថ្ងៃក្រោយចង់តម្លើងមហិទ្ធិរិទ្ធិអី ទៅចឹកចង់ធ្វើអីគេក៏មិនបាន ព្រោះអស់ពិសរលីងលែងមានមហិទ្ធិរិទ្ធិឥទ្ធិពលអីទៀតទេ ទើបបានជាមានពាក្យចាស់បុរាណពោលថា៖ "អាថ្លាន់អើយប្រយ័ត្នអាថ្លាន់ កុំអីឡើង ចេះតែឲ្យគេអស់ៗអស់ពីខ្លួនរលីងណា!"

ខ្ញុំពីដើមឆ្ងល់ដែរពីពាក្យចាស់ៗជេរ**អាថ្លាន់**នេះ ព្រោះមិនទាន់ដឹងពីប្រវត្តិពស់ថ្លាន់ៗ ពេលដឹងប្រវត្តិពស់ថ្លាន់ ទើបដឹងថាអូមែន! ពស់ថ្លាន់ពីដើមពូកែមែន តែឥឡូវគេចាប់តែនឹងដៃយកទៅប្ដឹងលក់រកម៉ែរកឪ បានលុយបានកាក់ចាយរាប់មិនឈ្នះទេៗ អាហ្នឹងរឿងប្រវត្តិពស់ថ្លាន់ ៕

# ១២- រឿងមនុស្ស និងសត្វគោ

## និទានដោយ លោកតា សោម នៅ [14]



14 ភូមិទន្លេបាទី ឃុំក្រាំងធ្នង ស្រុកបាទី ខេត្តតាកែវ។

មនុស្សយើងតែងមានចម្ងល់ថា ហេតុអ្វីបានជាកូនគោពេលកើតមកភ្លាមវាអាចដើរបាន ឯមនុស្សវិញមិនអាចកើតភ្លាមដើរបានដូចគោ?

មានរឿងនិទានតំណាលពីមនុស្សនិងគោថា៖

កាលពីមុន មនុស្សយើងនេះកើតមកភ្លាមចេះដើរភ្លាម ឯគោកើតមកខ្វិន ទាល់តែបានអាយុ១ឆ្នាំទើបចេះដើរបាន។

ព្រឹកថ្ងៃមួយនោះ មានខ្លាសាហាវមួយចាប់ផ្ដើមចេញដើររកចំណីឲ្យកូន។ លុះដើរៗទៅ ខ្លាក៏ទៅជួបនឹងកូនគោមួយក្បាលដែលទើបតែកំពុងរៀនដើរ។ ឃើញដូច្នោះ ខ្លាក៏ចូលទៅរកកូនគោនោះបម្រុងចាប់ស៊ី តែត្រូវមេគោចូលមកទាន់ ហើយនិយាយយាត់ថា៖ "ឈប់សិនបងខ្លា! បើបងខ្លាឯងចង់បានកូនខ្ញុំយកទៅឲ្យកូនបងខ្លាឯងហូប សូមបងយកខ្ញុំវិញចុះ ព្រោះខ្ញុំធំជាង! ប៉ុន្តែសូមចាំឲ្យខ្ញុំទៅឲ្យកូនបៅមួយចម្អែតសិន!"

មេខ្លាក៏ត្រលប់ទៅប្រាប់កូនខ្លួនវិញថា៖ "ថ្ងៃនេះយើងបានចំណីហូបហើយ!"

"បានចំណីហូបយ៉ាងម៉េច?" កូនខ្លាសួរ។

"ម៉ែមានមេគោមួយកំពុងតែបំបៅកូន។ កូនឯងប្រាកដជាបានចំណីហូបហើយ មិនបាច់បៅដោះម៉ែទេ ព្រោះដោះម៉ែផ្ដាច់ចោលបាត់ហើយ!" ម្ដាយឆ្លើយ។

មួយស្របក់ក្រោយមក មេខ្លាក៏ដើរត្រលប់ទៅរកមេគោវិញ។ ពេលវាឃើញមេគោហើយ វាក៏ដើរសំដៅទៅរកមេគោនោះ។ ទន្ទឹមពេលនោះ ព្រះអង្គក៏និមិត្តធ្វើជាសត្វប្រើសមួយឈរនៅជិតទីនោះដែរ។ ពេលខ្លាក្រលេកឃើញសត្វប្រើស វាក៏ពិចារណាថា៖ "គេក៏ស្រលាញ់កូនគេ អញក៏ស្រលាញ់កូនអញ។"

គិតហើយ ខ្លាក៏លែងទៅចាប់គោ ហើយក៏ងាកទៅដេញចាប់សត្វប្រើសវិញ។ ខ្លាខំដេញចាប់សត្វប្រើស តែចាប់មិនបានសោះ ទីបំផុតដោយអំណាចនៃកម្ម វាក៏រត់ទៅធ្លាក់ក្នុងអន្លង់មួយចេញមិនរួចសោះ។ គាប់ជួនមនុស្សដើរមកឃើញខ្លានៅក្នុងអន្លង់ក៏ស្រែកប្រកូកប្រកាសហៅគ្នីគ្នាថា៖ "បងប្អូនអើយ យកច្បូកយកដំបងមកវាយខ្លា ខ្លាធ្លាក់ក្នុងអណ្ដូងហើយ!"

ប្រជាជនអ្នកស្រុកអ្នកភូមិក៏នាំគ្នាមកវាយសំពងខ្លាយ៉ាងចាស់ដៃរហូតដល់ខ្លាសន្លប់។

ខ្លាដឹងខ្លួនឡើងមកហើយក៏តាំងសតិពិចារណាឡើងវិញខំប្រឹងឡើងពីអន្លង់ តែនៅតែឡើងមិនរួចដដែល។

លុះចេញមិនរួចដូចនេះ ខ្លាក៏នឹកឃើញដល់បាលីអច្ឆរិយ ទើបវាក៏អាចលោតចេញពីអន្លង់នោះរួច ហើយក៏ខំប្រឹងដើរទៅមុខទៀត។ ដើរៗទៅ ខ្លាក៏ទៅជួបនឹងព្រះអង្គដែលកំពុងនិមន្តដើរ។ គ្រាន់តែក្រឡេកឃើញព្រះអង្គភ្លាម ខ្លាខំប្រឹងដើរទាំងទ្រេតទ្រោតសំដៅទៅរកព្រះអង្គ។ ពេលទៅដល់ វាលុតជង្គង់ថ្វាយបង្គំព្រះអង្គ។ ព្រះអង្គក៏មានព្រះដីកាថា៖ "ម្នាលខ្លា! ពីពេលនេះទៅឯងនឹងមានពាររហូតគឺដោះខ្លាឯងនឹងដាច់ម្ដងមួយៗដោយសារតែកូនខ្លួនឯងខាំ ពេលឯងមានកូនមួយៗមក។ ចំណែកសត្វគោវិញគោចូរឲ្យកើតមកចេះដើរ ឯមនុស្សវិញចូរឲ្យកើតមកខ្វិនអត់ចេះដើរដូចគោកាលពីមុនវិញម្ដង។

ដោយសារតែព្រះអង្គដាក់ទំនាយដូច្នេះហើយ ទើបតរហូតមកទល់សព្វថ្ងៃនេះ ពេលមនុស្សកើតមកតែងមិនចេះដើរភ្លាមៗទេ ហើយត្រូវម្ដាយចិញ្ចឹមបីបាច់រក្សាសិន។ ចំណែកឯគោវិញ គ្រាន់តែកើតមកភ្លាមក៏អាចដើរបានតែម្ដង។ រីឯខ្លាវិញ គេរមែងមានជំនឿថា ខ្លាមួយមានកូនម្ដងតែមួយទេ ហើយក៏មិនអាចមានកូន

ភ្លោះពីរដែរ។ ឯដោះរបស់វាវិញនឹងដាច់ម្ដងមួយៗដោយសារកូនវាខាំនៅពេលវាមានកូនមួយៗមក រហូតដល់លែងមានដោះឲ្យកូនបៅ។ ទឹកដោះខ្លាមានរសជាតិផ្អែម ផ្អែមជាងទឹកដោះគោ ហើយទឹកដោះខ្លានេះ បើសិនមនុស្សយកមកហូបវិញ ធ្វើឲ្យចិត្តគេហ៊ានណាស់។ រីឯពុកមាត់វិញមានជាតិពុល។ បើដាក់លាយជាមួយស្រាវានឹងមានពណ៌ខៀវឬទឹកប៊ិច ដូចសម្ផ្លោត ដូចផ្កាត្នោត ឬដូចផ្កាត្រកៀត។ បើយើងហ៊ានហូបវាលាយជាមួយស្រាឬទឹក ពោះវៀនយើងនឹងធ្លាយដាច់ខ្ទេចខ្ទី ហើយពុលរហូតដល់លៀនភ្នែក។ ចំណែករោមខ្លាវិញវាមិនមានគ្រោះថ្នាក់អ្វីឡើយ៕

# ១៣- ប្រវត្តិរឿងអ្នកតាឃ្លាំងមឿង

និទានដោយលោក ម៉ៅ សោភ័ណ [15]

15 ភូមិកំពែងស្វាយ ឃុំស្នាមព្រះ ស្រុកបាកាណ។

ពេលធ្វើបុណ្យឡើងរោងអ្នកតាឃ្លាំងមឿងម្ដងៗនៅក្នុងខេត្តពោធិ៍សាត់ គេនិមន្តព្រះសង្ឃធ្វើបុណ្យដាក់បាត្រសែនព្រេនបីថ្ងៃដើម្បីឧទ្ទិសដល់លោកតា។ មានប្រជាជនច្រើនកុះករគ្រប់លំដាប់ថ្នាក់មកពីតំបន់ផ្សេងៗទូទាំងប្រទេសកម្ពុជាមកចូលរួមក្នុងពិធីនេះ ដើម្បីសុំសេចក្ដីចំរើនក្នុងជីវភាពគ្រួសារ មុខរបររកស៊ីអីជាដើម។ ជាធម្មតាមានមនុស្សគ្រប់ប្រភេទមកបន់ស្រន់នៅកន្លែងអ្នកតាឃ្លាំងមឿងនេះ ជាពិសេសពួកកងទ័ពទាហានមកបន់សុំសុខពេលចេញធ្វើសង្គ្រាមនិងធ្វើដំណើរផ្លូវឆ្ងាយ ហើយលោកតាក៏ចូលចិត្តទាហានទ័ពដែរ។ ពេលគេមកសុំបន់ស្រន់តែងបានសំរេចដូចបំណងរបស់គេមែន ហើយពេលបានសំរេច គេតែងមកសែនលាបំណន់វិញ។ ដូចនេះបានជាប្រជាជនមានជំនឿលើលោកតាឃ្លាំងមឿងខ្លាំងណាស់បច្ចុប្បន្ននេះ។ តែការបន់ស្រន់មានតាំងពីយូរយាណាស់មកហើយ គឺតាំងពេលដែលលោកតាលោតសម្លាប់ខ្លួនមកម្ល៉េះ។[16]

16 ពេលថ្ងៃឡើងរោង ព្រលឹមឡើងគេនិមន្តព្រះសង្ឃមកដាក់បាត្រ។ សម័យឥឡូវនេះគេនិមន្តព្រះសង្ឃមកចូលរួមពិធីបុណ្យរាប់រយអង្គពេលធ្វើពិធីម្ដងៗ។ ហើយបន្ទាប់ពីដាក់បាត្រព្រះសង្ឃរួចហើយ គេរៀបចំពិធីសែនឡើងរោង។ បើនិយាយទៅតាមប្រវត្តិពីដើមសម័យព្រះអង្គច័ន្ទរាជាវិញ គេសែនសុទ្ធតែក្បាលជ្រូក ស្រាខ្លួច ស្រាទឹង ផ្លែឈើដាក់សុទ្ធតែតោកជង្ហាយលោកតា។ មកដល់សម័យកណ្ដាល សម័យសង្គមរាស្ត្រនិយមព្រះករុណាលោកតែងតែរៀបចំឲ្យមានបុណ្យឡើងរោងជូនលោកឧកញ៉ារាល់ឆ្នាំដែរ។ សម័យនោះរណ្ដាប់ដែលសែនមាន១៣មុខ តែមកដល់បច្ចុប្បន្ននេះ រណ្ដាប់ដែលរៀបចំសែនលោកតា ដូចជាវាមិនអាចទៅរកក្បាលជ្រូក ក្បាលអីណាមកទេ អញ្ចឹងបវរណាក្បាលជ្រូក ក្បាលមាន់ ស្ងោរមាន់មកជំនួសវិញ។ គ្រឿងរណ្ដាប់វិញមិនត្រឹមតែ១៣មុខតាមទំនៀម តែបច្ចុប្បន្ននេះមានច្រើនសន្ធឹកសំបូរហូរហៀពេកណាស់ ពូនសែនពាសពេញទាំងអស់ ព្រោះអស់លោកមកពីណាគេចង់ដាក់ស្អីៗហ្នឹងស្រេចតែគេទៅ។ និយាយរួមបុណ្យនេះមិនមែនបុណ្យរបស់បុគ្គលណាម្នាក់ដែរ គឺយើងទាំងអស់ធ្វើដើម្បីតបស្នងគុណលោកតា! ខ្ញុំជាអ្នកផ្ដើមធ្វើពិធីដោយសារខ្ញុំមានតួនាទីជាអ្នករក្សា ហើយជាអ្នកផ្ដើមផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ ចែកសំបុត្រ

រឿងហ្នឹងកើតឡើងតាំងពីសម័យព្រះអង្គច័ន្ទរាជាដែលឈ្លោះជាមួយនឹងស្តេចកនម្ល៉េះ។ ក្នុងពង្សាវតាខ្មែរ គេនិយាយថាស្តេចកននេះជារាស្ត្រសាមញ្ញ ឯព្រះអង្គច័ន្ទរាជាមានពូជពង្សជាខ្សែស្តេច។ នាយកនបានទៅជាប្អូនថ្លៃស្រីសុគន្ធបទ ឯស្រីសុគន្ធបទជាបងរបស់ព្រះច័ន្ទរាជា។ ដូចនេះស្តេចកនក៏ជាប់ទាក់ទងនឹងញាតិវង្សស្តេច។ ពេលបានជាស្តេចកនក៏រកកលឧបាយសម្លាប់ព្រះអង្គច័ន្ទរាជាដែលជាស្តេចសោយរាជ្យនាពេលនោះ តែព្រះអង្គច័ន្ទរាជាដឹងផែនការមុនដូចជាមិនស្រួល ចេះតែទើសអញ្ចេះអញ្ចុះខ្លាចស្តេចកន។ អញ្ចឹងព្រះអង្គច័ន្ទរាជានឹកឃើញក៏រត់កៀសខ្លួនទៅនៅស្រុកសៀមមួយរយៈដើម្បីលាក់ខ្លួនពួនអត្មានៅទីនោះ។

ដល់ពេលព្រះអង្គចន្ទ័រាជាទៅផុត ស្តេចកនបានដៃក៏រុករានទន្ទ្រានរៀបចំបណ្តាញពង្រីកអំណាចកម្លាំងរបស់ខ្លួន រហូតដល់សម្លាប់ស្រីសុគន្ធបទបាន ហើយក៏តាំងខ្លួនឯងជាអធិរាជស្តេច។ ដំណឹងនេះបានដឹងដល់ទៅព្រះអង្គច័ន្ទរាជានៅឯក្រុងទេពបុរីស្រីអាយុធ្យា។ ព្រះអង្គក៏រៀបចំខ្លួនចូលមកស្រុកវិញ ដោយប្រាប់ស្តេចសៀមថាមកទាក់ដំរីសម្តងនៅស្រុកខ្មែរ។ ដល់លើកទី២ ស្តេចអង្គច័ន្ទរាជាក៏កុហកស្តេចសៀមថាមកទាក់ដំរីសទៅថ្វាយព្រះចៅក្រុងទេពបុរីទៀត តែតាមពិតលើកនេះព្រះអង្គច័ន្ទរាជាមកធ្វើសង្គ្រាមជាមួយនឹងស្តេចកនទៅវិញ។ ដោយបាត់ដំណឹងព្រះអង្គច័ន្ទរាជាយូរពេក ស្តេចសៀមក៏បញ្ជាឲ្យព្រះសិទ្ធានចៅពញ៉ាអុងដឹកនាំទ័ពមកដេញតាមព្រះច័ន្ទរាជាពីប្រទេសសៀមមកប្រផឹតប្រផោយព្រោះដឹងថាអង្គច័ន្ទរាជាមិនមែនមកទាក់ដំរីទេ គឺព្រះអង្គកៀសខ្លួនមកចូលស្រុកវិញ។

---

ស្នាមទៅញាតិមិត្តជិតខាងក្បែរហ្នឹង។ ដល់ពេលយប់ឡើង គេមានលេងរបាំល្ខោនជាតិរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈសំដែងជារឿងប្រវត្តិលោកឧកញ៉ាឃ្លាំងមឿង។

ព្រះអង្គច័ន្ទរាជាចូលមកស្រុកខ្មែរវិញក្នុងបំណងមកប្រល័យស្ដេចកន។ ដល់ពេលប្រយុទ្ធ ទ័ពព្រះអង្គចន្ទរាជាចូលមកដល់ពោធិ៍សាត់ ឯទ័ពស្ដេចកនមកដល់ស្រុកក្រគរ[17]។ មកដល់ទីហ្នឹងទ័ពខាងស្ដេចកនមានច្រើនជាង អញ្ចឹងទ័ពព្រះអង្គច័ន្ទរាជាមើលទៅទប់ទល់ជាមួយទ័ពស្ដេចកនមិនកើតក៏គិតដកខ្លួនថយមកបោះទីតាំងនៅពោធិ៍សាត់ជាបណ្ដោះអាសន្នមួយរយៈសិន ដើម្បីត្រៀមកម្លាំងសារជាថ្មីក្នុងបំណងធ្វើម៉េចផ្ដួលរលំស្ដេចកនឲ្យបាន។ អញ្ចឹងក៏ប្រើកូនតាមឿងពីរនាក់ឲ្យដឹកនាំទ័ពចេញច្បាំងមួយវរៈដើម្បីស្ទាបស្ទង់មើលទ័ពខាងស្ដេចកន។ កូនតាមឿងទាំងពីរនាក់មើលទៅឃើញទ័ពគេច្រើនណាស់ អញ្ចឹងក៏ដកថយទៅប្រាប់តាមឿងវិញ។ ដោយមិនអស់ចិត្ត ព្រះអង្គច័ន្ទរាជាក៏ឲ្យតាមឿងទៅម្ដងទៀត។ តាមឿងមើលទៅហាក់ដូចជាមិនស្រួលទេព្រោះទ័ពសុទ្ធតែខ្មែរដូចគ្នា ក៏រកមធ្យោបាយយ៉ាងម៉េចដើម្បីយកជ័យជំនះកុំឲ្យខាតកម្លាំងច្រើនពេក។

តាមឿងក៏ទៅទូលព្រះច័ន្ទរាជាថា៖ "ទូលបង្គំមានគំនិតមួយដើម្បីយកមកជួយព្រះអង្គ ជួយយកអាសារទឹកដី។"

ព្រះច័ន្ទរាជាសួរថា៖ "មានគំនិតអី?"

តាមឿងថា៖ "ករុណាសុំព្រះអង្គទៅកេណ្ឌទ័ពខ្មោច!"

ព្រះអង្គថា៖ "ដូចជាមិនដែលមានអញ្ចឹងទេកន្លងមក មិនដែលអ្នកណាសម្លាប់ខ្លួនហើយទៅកេណ្ឌទ័ពខ្មោចមកជួយច្បាំងមនុស្សទេ ដល់អញ្ចឹងព្រះអង្គច័ន្ទរាជាដាក់ងារលោកតាមឿងថាលោកតាអ្នកពញាសួគ៌ា ហើយថាឲ្យគិតរកគំនិតអីផ្សេងទៀតទៅ កុំធ្វើអញ្ចឹងព្រោះវាប៉ះពាល់ដល់អាយុជីវិតចៅពញា!"

---

17 ពីដើមគេហៅថាខេត្តក្រគរពោធិ៍សាត់។

ព្រះអង្គព្យាយាមឃាត់តាមឿងមិនឲ្យធ្វើអញ្ចឹងទេ ឲ្យតាមឿងគិតរកមធ្យោបាយបែបផ្សេងទៅ តែតាមឿងគិតថាគ្មានមធ្យោបាយផ្សេងទៀតទេ។ ដូចនេះគាត់ក៏សុខចិត្តសម្លាប់ខ្លួនដើម្បីទៅប្រមូលទ័ពខ្មោចមកជួយធ្វើសង្គ្រាម មកពីតាមឿងហ្នឹងមើលឃើញថា ទ័ពនៅឯនោះក៏ជាខ្មែរយើងដែរ ហើយទ័ពរបស់តាមឿងក៏ជាខ្មែរដែរ បើសិនជាខ្មែរដូចគ្នាអញ្ចឹង ខ្មែរនិងខ្មែរវាយគ្នាដូចនេះទើបជាលោកតាថា៖ "អេ សុខចិត្តសម្លាប់ខ្លួនឯងទៅកេណ្ឌទ័ពខ្មោចយកមកជួយ!"

ទោះបីព្រះច័ន្ទរាជាខំឃាត់តាមឿងមិនឲ្យធ្វើ តាមឿងនៅតែមិនយល់ព្រមទេ បានព្រះអង្គច័ន្ទរាជាថា៖ "អើមឿងឯងមានវីរៈភាពយ៉ាងនេះធ្វើអីធ្វើទៅ មិនហ៊ានហាមឃាត់ទេ ព្រោះតាមឿងថាបើមិនសម្លាប់ខ្លួនទេក៏អាករដែរ។"

តាមឿងក៏បញ្ជាឲ្យគេជីករណ្ដៅ៨ហត្ថ៤ជ្រុងជំរៅ៨ហត្ថ ហើយធ្វើរបងព័ទ្ធជុំវិញ ធ្វើរានទេវតា៨ទិស រៀបបាយសី៥ថ្នាក់៣ជាន់ ប៉ាកតាម ទឹកអប់ធ្វេងស្ដាំ លេងរកភ្លេងកំដរក្នុងពិធី រួចហើយទើបលោកតាមឿងលោតសម្លាប់ខ្លួនទៅ។

បន្ទាប់ពីលោកតាលោតសម្លាប់ខ្លួនទៅ ជំទាវខាន់ខៀវជាស្នំឯករបស់ស្ដេចអង្គច័ន្ទថា បើលោកតាលោតសម្លាប់ខ្លួន ជំទាវខាន់ខៀវក៏សុខចិត្តលោតសម្លាប់ខ្លួនដើម្បីតាមទៅប្រមូលទ័ពបិសាចដូចតាមឿងដែរ និងតាមបម្រើលោកតាមឿង។ ដូចនេះជំទាវខាន់ខៀវក៏ប្ដេជ្ញាលោត ហើយកូនប្រុសលោកតា២នាក់ក្នុងចំណោម៤នាក់[18] ក៏ប្ដេជ្ញាលោតតាមដែរ។ អញ្ចឹងបានក្នុងរណ្ដៅតែមួយលោត៤នាក់ តាមឿង១ ជំទាវខាន់ខៀវ១ កូនប្រុស២

18 កូនទាំងបួននាក់នេះខ្ញុំមិនចាំឈ្មោះទេ។

លោតសម្លាប់ខ្លួនក្នុងយប់តែមួយៗ យប់នោះជាខែពិសាខហើយវាត្រូវខ្នើតទៀតផង ខែពិសាខបានខ្ញុំហ៊ានថាខ្នើត ពីព្រោះអីសំដីលោកតាមឿងលោកថា៖ " ពេលដែលគាត់មុននឹងលោតគាត់ប្រាប់សំលាញ់របស់គាត់ឲ្យដឹងថាសំលាញ់ឯងចាំមើលថាយប់ថ្ងៃ១៥កើតពេញបូរមីៗ" នេះសំដីដែលលោកតាមឿងបញ្ជាក់ប្រាប់លោកតាសំលាញ់របស់គាត់ថា៖ "១៥កើតពេញបូរមីខែពិសាខ ឯងចាំមើល ម៉ោង១២អាធ្រាតនឹងមានសន្ធឹកខ្ទរខ្ទារពេញព្រៃព្រឹក្សាលតាវល្លិ ញ័រដីញ័រទឹក កក្រើកទឹក កក្រើកដី ឯងទៅទូលព្រះមហាក្សត្រ ដើម្បីឲ្យលោកបើកយុទ្ធាការអញ្ចឹងទៅណា![19]"

ដល់លោកតាមឿងគាត់នឹកឃើញថា សង្គ្រាមនេះគឺខ្មែរនឹងខ្មែរវាយគ្នា ដោយមានទ័ពសៀមមកដេញតាមព្រះអង្គច័ន្ទរាជាផង ដូច្នេះដំបូងបំផុតតាមឿងគឺដេញពួកទ័ពសៀមសិន ទើបមានការប្រយុទ្ធជាមួយទ័ព

19 មកពីលោកតាមឿងលោតសម្លាប់ខ្លួនក្នុងថ្ងៃ១៥កើត ខែពិសាខ អញ្ចឹងបានសព្វថ្ងៃគេនាំគ្នាធ្វើបុណ្យឡើងលោកតាខែពិសាខ ប៉ុន្ដែឲ្យចំថ្ងៃសុក្រ សៅរ៍ អាទិត្យ ថ្ងៃពេញបោរផង ព្រោះវាងាយស្រួលមន្ត្រីរាជការមកចូលរួមធ្វើបុណ្យផងដែរ តែទោះបីជាចំក្ដីមិនចំក្ដី អ្នកស្រុកពោធិ៍សាត់ធ្វើតាំងពីឆ្នាំ១៩៧៩ នាំគ្នាលួចធ្វើបុណ្យកាលយើងចេញពីប៉ុលពតមក ពួកទ័ពវៀតណាមនៅពេញទឹកពេញដី យើងអត់ហ៊ានធ្វើអី អញ្ចឹងចេះតែនាំគ្នាលួចធ្វើទៅធ្វើស្ងាត់ៗនិមន្តលោកមកធាន់បង្សុកូលទៅៗ តាំងពីនោះរហូតមក យើងចេះតែពង្រីកការធ្វើបុណ្យរបស់យើង ប៉ុន្ដែបុណ្យគេធ្វើតាំងពីសម័យព្រះអង្គច័ន្ទរាជាមកម៉េះ ព្រោះអីនៅពេលដែលលោកតាមឿងលោតចូលក្នុងរណ្ដៅសម្លាប់ខ្លួនហើយ ព្រឹកឡើងហ្នឹងគឺព្រះអង្គច័ន្ទរាជាលោកនិមន្តព្រះសង្ឃធ្វើបុណ្យតែម្ដងដើម្បីឧទ្ទិសកុសលជូនលោកតា កូនទាហានធ្វើបុណ្យនៅទីនោះរហូតមកទល់សព្វថ្ងៃទីហ្នឹងៗ គេហៅបន្ទាយជ័យ ជុំវិញបរិវេណហ្នឹង សព្វថ្ងៃយើងនៅមានឈ្មោះភូមិមួយឈ្មោះភូមិបន្ទាយជ័យ ប៉ុន្ដែទីនេះស្ថិតនៅភូមិកំពែងស្វាយបច្ចុប្បន្ន ប៉ុន្ដែទីនោះខាងត្បូងមានភូមិបន្ទាយជ័យ ទៅខាងត្បូងបន្ទាយជ័យងាកទៅនោះមានភូមិមួយទៀត ភូមិជុំរុំសៀម កាលនោះជាកន្លែងដែលសៀមមកទីតាំងដើម្បីត្រៀមៗ

ស្តេចកនៗ ដល់ពេលធ្វើពិធីនាថ្ងៃ១៥កើត ចាប់ពីម៉ោង១២រំលងអាធ្រាតទៅ វាមានបាតុភូតមួយកើតឡើង យើងមើលមិនឃើញទេ ប៉ុន្តែឃើញទ័ពខ្មាំងសត្រូវភាគច្រើនកើតចុកចុះភ្លួតប្រកាច់អឺអញ្ចឹងទៅៗ កូនតាមឿង ២នាក់ដែលនៅរស់ហ្នឹងចាប់ចេញដឹកនាំទ័ពប្រយុទ្ធ ហើយតាមឿងគាត់ជាអ្នកនៅពីក្រោយកេណ្ឌទ័ពខ្មោចជួយក្នុងការប្រយុទ្ធ រហូតដល់ត្រឡែងកែងលង្វែកឫស្សីបែកគុម្ពៗ[20] ពេលហ្នឹងទ័ពខាងៗស្តេចអង្គច័ន្ទរាជាក៏វាយឈ្នះទ័ពស្តេចសៀម និងទ័ពស្តេចកនបានជ័យជំនះទូទាំងប្រទេសណា៕

---

20 រូបលោកតាឃ្លាំងមឿងមាននៅគ្រប់ទីកន្លែង នៅត្រង់ទួលត្រឡែងកែងខេត្តកំពង់ស្ពឺមានទួលមួយសព្វថ្ងៃគេហៅថាទួលឧកញ៉ាឃ្លាំងមឿងៗ នៅទន្លេបាទីក៏មានកន្លែងលោកតាមឿងៗ នៅកំពតក៏មានទួលលោកតាឃ្លាំងមឿងៗ ព្រោះតែទ័ពលោកតាមឿងទៅដល់កន្លែងណាគេបោះជំរំនៅទីនោះៗ ដូចនោះហើយកន្លែងទាំងនោះក្លាយជាទីសក្ការៈបូជាៗ គេតែងរៀបចំធ្វើពិធីគោរពបូជាដើម្បីឧទ្ទិសដល់កេរ្តិ៍ឈ្មោះលោកតា និងបន់ឲ្យលោកតាជួយ ពិសេសកូនប្រុសៗសុំឲ្យលោកជួយៗ

# ១៤- រឿងកូនសេដ្ឋី និងសត្វត្រដក់

## និទានដោយលោកអ៊ុំ អិន អៀន [21]



21 *ភូមិសំបួរមាស១ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។*

ខ្ញុំគ្មានរឿងកំប្លែងសើចទេ តែមានរឿងមួយ រឿងហ្នឹងវែងបន្តិច ដូច្នេះខ្ញុំនិយាយកាត់ៗទេណា!

ខ្ញុំតំណាលអំពីរឿងបុត្រីសេដ្ឋីម្នាក់ៗ សេដ្ឋីហ្នឹងមានកូនស្រីមួយ គាត់តែងឲ្យកូនស្រីគាត់ផ្ទំម្ចប់ៗ លុះរួចពីផ្ទំម្ចប់ទៅ ថ្ងៃមួយនាងអផ្សុកខ្លាំងណាស់ ក៏គិតចង់លាឪពុកចេញទៅកំសាន្តនៅសួនច្បារនៅឆ្ងាយពីផ្ទះប្រហែលជា១០០ម៉ែត្រ ដើម្បីយកខ្យល់អាកាសៗ ឪពុកក៏យល់ព្រម តែចាត់ឲ្យមីនំមីនាង គិលៀង សេនាពីរបីនាក់ទៅជាមួយដែរៗ កូនសេដ្ឋីហ្នឹងមានឆ្កែខ្មៅមួយធំហើយចេះដឹងណាស់ វាស្រលាញ់ម្ចាស់វា ទៅណាក៏វាទៅតាមដែរៗ ដល់ពេលដើរលេងកំសាន្តក្នុងសួនច្បារ សត្វឆ្កែនោះក៏ទៅជាមួយដែរៗ

និយាយពីស្ដេចត្មាតវិញម្ដងៗ ស្ដេចត្មាតអផ្សុកខ្លាំងណាស់គិតចង់លាប្រពន្ធចេញមកកំសាន្តព្រៃៗ វានិយាយទៅកាន់ប្រពន្ធថា៖ "ឯងអើយ! នៅចាំទីកន្លែងយើងឲ្យបានល្អត្រឹមត្រូវ ហើយមើលកូនមើលចៅឲ្យបានល្អផងៗ"

ថាហើយ ស្ដេចត្មាតក៏នាំទ័ពយោធាត្មាតរបស់ខ្លួនហោះចេញមកលេងមើលក្នុងព្រៃក្រែងលោមានសត្វម្រឹគីម្រឹគាណាងាប់គ្រាន់បានយកមកធ្វើចំណីខ្លួនៗ ទ័ពត្មាតទាំងអស់បានហោះឡើងលើមេឃឡើងល្ងិតថ្ងៃមួយចំហៀងមេឃ ព្រោះហ្វូងត្មាតនេះច្រើនណាស់ៗ ដល់ពេលដែលហ្វូងត្មាតទាំងនោះហោះមក ស្រាប់តែបានឃើញនាងពៅជាកូនសេដ្ឋីស្រែកច្រៀងស័កវា វេរាំ រាំលេងក្នុងសួននោះៗ ពេលឃើញដូចនោះ ស្ដេចត្មាតក៏ហើរបន្ទាបខ្លួនមកហើយថ្លែលលិចថ្លែលកើត ឱជងតាមសំដីភាសាសត្វ ហួចទៅវិញទៅមកទៅកាន់មនុស្ស ហើយសត្វត្មាតសួរទៅនាងពៅថា៖ "នាងពៅធីតាអើយ! ឥឡូវឲ្យយើងសុំឆ្កែរបស់នាងមក នាងទុកវាធ្វើអ្វីទៀត ព្រោះយើងកំពុងតែដើររកចំណីអាហារ!"

កូនសេដ្ឋីក៏ឆ្លើយវិញថា៖ "អាសត្វត្មាតផេះផ្លុះផោង កុំសំដីកាចកោងមកលើយើង ឯងកុំមកជិតមនុស្សលោក យើងជាមនុស្សលោក ឯងជាត្មាតផេះផ្លុះផោងហ្នឹងទៅឲ្យឆ្ងាយទៅ!"

ដោយសារតែការសារសេង និងដាក់ផ្ទៃដាក់ផ្កា ប្រាស់ផ្លុះគ្នាទៅវិញទៅមកដូច្នេះ ស្ដេចត្មាតក៏ខឹងនឹងកូនស្រីសេដ្ឋីយ៉ាងខ្លាំង តែមិនដឹងធ្វើម៉េច ក៏នាំទ័ពខ្លួនត្រលប់ទៅកន្លែងវិញ។

ពេលមកដល់ទ្រនំវិញ ស្ដេចត្មាតកើតទុក្ខមិនសុខចិត្ត នឹកគុំខឹងនិងកូនសេដ្ឋី ក៏លាប្រពន្ធដោយសម្ងាត់មកតែម្នាក់ឯង លើកនេះមិនយកកូនចៅមកជាមួយទេ។ មកដល់ផ្ទះសេដ្ឋី ត្មាតក៏ប្រែក្រឡាខ្លួនជាមាណពម្នាក់យ៉ាងស្រស់ស្អាត ហើយក៏ដើរចូលមកទៅកាន់ផ្ទះសេដ្ឋី ថ្លែងថែងវាចាប្រាប់សេដ្ឋីថា៖ "ខ្ញុំនេះជាមាណពកំសត់ម្នាក់គ្មានម្ដាយឪពុកទេ ក៏ប៉ុន្ដែថ្ងៃមួយនោះខ្ញុំឃើញកូនលោកមហាសេដ្ឋីបានចេញទៅលេងសួនច្បារ ហើយខ្ញុំពេញចិត្តពេញថ្លើមនឹងនាងណាស់ ដូចនេះខ្ញុំសូមមកចូលគាល់ដល់លោកមហាសេដ្ឋីដើម្បីចងស្ពានមេត្រីស្ដីដណ្ដឹងផ្ទាល់ដល់លោកម្ចាស់តែម្ដង តើបានឬមិនបានលោកសេដ្ឋី?"

មាណពក្លែងខ្លួនក៏សូត្រធម៌មន្តអាគមគាថាដើម្បីបន្ទន់ទឹកចិត្តសេដ្ឋីនីជាប្រពន្ធនិងសេដ្ឋីជាឪពុកសព្វគ្រប់បែបយ៉ាង។

សេដ្ឋីក៏តបថា៖ "បើអញ្ចឹងមិនជាការទាស់អីទេ គ្មានការខឹងសម្បារចងគំនុំគុំគួនអីឡើយ! បើអ្នកឯងថាពេញចិត្តនឹងកូនស្រីរបស់យើងហើយ យើងក៏មិនខឹងសម្បារអីដែរ បើអញ្ចឹងព្រមព្រៀងគ្នារៀបចំមង្គលការទៅ។"

ដល់រៀបការរួច មាណពក្លែងខ្លួននាំប្រពន្ធលាឪពុកម្ដាយហ្នឹងទៅលេងផ្ទះសម្បែង ខាងស្រុករបស់ខ្លួន

ម្តង តែតាមពិតគំនិតវាគិតថា៖ "បើកាលណានាំទៅដល់ពាក់កណ្តាលព្រៃស្ងាត់ត្មាតនោះនឹងស៊ីនាងហ្នឹងជាការសងសឹក។"

ឯនាងជាប្រពន្ធអត់ដឹងទេ ដល់អញ្ចឹងមាណពក៏នាំប្រពន្ធទៅ។ ពេលដើរទៅដល់ដើមជ្រៃមួយធំ មាណពថា៖ "អូននៅអង្គុយសម្រាកនៅហ្នឹងសិនចុះ ចាំបងទៅរកផ្លែឈើផ្លែព្រៃយកមកឲ្យអូនហូបនៅពេលនេះ!"

នាងនោះក៏យល់ព្រម ហើយត្មាតក៏ចេញពីទីម្ងប់ដើមជ្រៃ កំបាំងភ្នែកប្រពន្ធហើយក៏កាឡាខ្លួនទៅជាសត្វត្មាតវិញហោះវឹងទៅ ដើម្បីទៅកេណ្ឌទ័ពរបស់ខ្លួនមកព្រួតស៊ីនាងហ្នឹង។ នាងកូនសេដ្ឋីអង្គុយនៅដើមជ្រៃម្នាក់ឯង ស្រាប់តែអារុក្ខអារក្ខទេវតាដែលនៅថែរក្សាដើមជ្រៃនោះបញ្ចេញព្ញតែសម្លេងនិយាយប្រាប់ទៅនាងនោះថា៖ "នែនាង! នាងឯងត្រូវដឹងខ្លួន ត្រូវប្រយ័ត្នខ្លួនឲ្យមែនទែន! ព្រោះថាប្តីនាងឯងអំបាញ់មិញជាស្តេចត្មាតទេ គេទៅនាំទ័ពរបស់គេមកស៊ីនាងឯងហើយ! បើអញ្ចឹងត្រូវចេញឲ្យផុតពីកន្លែងនេះ ឲ្យស្រូតទៅ ពីព្រោះស្តេចត្មាតគេមានកែវត្មាតរបស់គេ ឥឡូវនាងឯងត្រូវស្រូតចេញពីកន្លែងនេះហើយដើរឆ្ពោះទៅទិសឥសាន បើកាលណាឃើញមានដើមជ្រៃធំមួយទៀតហើយមានរូងនៅទីនោះ នាងឯងត្រូវស្រូតរូតរត់ពួនក្នុងរូងនោះ ទើបបានសុខខ្លួន! មិនអីទេនាង! ចាំយើងតាមជួយថែរក្សា។"

ព្ញដូច្នេះ នាងនោះភ័យយ៉ាងខ្លាំង ក៏រត់ចេញពីដើមជ្រៃនោះភ្លាមហើយដើរសំដៅទៅដើមជ្រៃមួយទៀតនៅទិសឥសាន ក៏ឃើញរូងដ៏ធំមួយ ហើយនាងរត់ចូលទៅពួនក្នុងរូងនោះ។ ចំណែកស្តេចត្មាតនាំទ័ពរបស់ខ្លួនហោះឡើងងងឹតមេឃចុះមក។ ពេលចុះមក ស្តេចត្មាតបើកកែវទៅឃើញថានាងហ្នឹងរត់ចេញពីដើមជ្រៃទៅទិសឥសានហើយ ពួកត្មាតមិនឃើញដូច្នោះ ក៏បោះពួយសំដៅទៅរកដើមជ្រៃមួយទៀតនៅទិសឥសាន ហើយ

ក៏បានឃើញរូងធំមួយៗ ប៉ុន្តែ រុក្ខទេវតាលោកនៅតាមថែរក្សានៅនោះ លោកជប់រុក្ខទេវតាមួយទៀតឲ្យកើតទៅជាតុកកែមួយយ៉ាងធំឲ្យនៅចាំរូងនេះ និងឲ្យពីងពាងមួយទៀតចាក់ស្រេះជាសំណាញ់រុំឲ្យជិតមាត់រូងនោះៗ

ស្ដេចត្មាតមកដល់ដើមជ្រៃហើយមិនឃើញនាងហ្នឹង បែរជាទៅឈ្លោះប្រកែកជាមួយនឹងតុកកែនិងពីងពាងនោះថា៖ "មានស្រីម្នាក់រត់មកពួននៅក្រោមដើមឈើនេះ អាតុកកែនិងពីងពាងឯងយកស្រីហ្នឹងទៅលាក់នៅឯណា? ត្រូវនាំនាងយកមកឲ្យយើង យើងនឹងយកនាងហ្នឹងធ្វើជាចំណីអាហាររបស់យើង! បើមិនអញ្ចឹងទេ យើងត្រូវស៊ីឯងទាំងអស់ហ្នឹង!"

តុកកែថា៖ "យើងមិនដឹងទេ! នែ! ឯងកុំចង់មកសម្លុតយើង! ចង់ធ្វើបាបយើងមិនបានទេ! ត្បិតតែថាឯងជាស្ដេចត្មាតក៏ដោយ!"

ដោយសារមានការប្រកែកប្រណាំងតវ៉ាគ្នាទៅវិញទៅមកអញ្ចឹង សត្វទាំងសងខាងក៏កើតមានការខឹងសម្បារនឹងគ្នា ហើយកើតមានការប្រកួតប្រជែងនឹងគ្នា តែស្ដេចត្មាតបរាជ័យមិនបានការអី ក៏ហោះផ្លែលឡើងល្ងិតព្រៃត្រលប់ទៅវិញៗ

បន្ទាប់មករុក្ខទេវតានិយាយប្រាប់នាងនោះថា៖ "ឥឡូវនាងកុំនៅទីនេះ នៅមិនបានទេ នាងត្រូវចេញពីកន្លែងនេះហើយសំដៅទៅជ្រុងទិសឥសានទៀតចុះៗ បើទៅជួបសត្វអីសុំសត្វនោះឲ្យជួយថែរក្សា ទើបនាងឯងរស់រានមានជីវិតតទៅមុខទៀត! ប៉ុន្តែនាងឯងមិនស្ដាប់ទេគ្រាន់តែកម្សត់!"

អញ្ចឹងនាងនោះក៏ចេញពីរូងដើមជ្រៃហើយរត់ទៅ ក៏ទៅជួបនឹងគោព្រៃមួយហ្វូងទៀតៗ សត្វត្មាតបើកកែវឃើតក៏ឃើញនាងនោះភ្លេត ភ្លាមនោះស្ដេចត្មាតក៏នាំកូនចៅសម្រុកបោះពួយទៅតាមនាងហ្នឹងទៀតៗ

ពេលត្មាតទៅជិតដល់ប្រផិតប្រផើយហើយនាងក៏ស្រែកថា៖ "បងគោព្រៃៗ! ជួយខ្ញុំផងៗ!"

គោព្រៃថា៖ "ជួយយ៉ាងម៉េច?"

នាងប្រាប់ថា៖ "បងហាមាត់ទៅឲ្យខ្ញុំចូលផង!"

គោព្រៃហ្នឹងក៏ហាមាត់ឲ្យនាងហ្នឹងចូលទៅក្នុងពោះខ្លួនទៅ។ ពេលទ័ពត្មាតមកដល់គ្រឹបក្ដាម ក៏ឈ្លោះប្រកែកជាមួយគោទៀត។ គោហ្នឹងក៏នាំគ្នាទល់ក្ដិតនិងក្ដិត ក្បាលចេញដោយខ្លួនប្រយុទ្ធគ្នាជាមួយស្ដេចត្មាតក្នុងព្រៃ។ ដោយសារមិនបានសម្រេច ស្ដេចត្មាតក៏ថយខ្លួនទៅទៀត។

គោក៏ខ្ជាក់ក្អួលនាងបញ្ចេញមកវិញហើយប្រាប់នាងថា៖ "នាងឯងនៅទីនេះពុំបានសុខទេ! ឥឡូវត្រូវចេញពីនេះទៅខាងមុខទៀត! បើមានជួបហ្វូងសត្វអីផ្សេងទៀត សុំគេជួយយកអាសារដូចហ្វូងគោពួកខ្ញុំអញ្ចឹងទៅ!"

ដូច្នេះនាងចេញពីមាត់គោហើយរត់ទៅមុខទៀត ក៏ជួបនឹងហ្វូងក្របីព្រៃមួយហ្វូងទៀត។ សត្វត្មាតឃើញនាងហ្នឹងក៏បោះពួយមកទៀត។ ពេលត្មាតបោះពួយមកជិតដល់ នាងនោះឃើញក៏ស្រែកហៅក្របីថា៖ "បងក្របីព្រៃជួយខ្ញុំផងៗ!"

ក្របីព្រៃក៏ហាមាត់ឲ្យនាងចូលជ្រក។ សត្វត្មាតក៏ប្រយុទ្ធជាមួយក្របីរហូតដល់បែកអាចម៍បែកនោម តែនៅមិនបានសម្រេចក៏ហោះត្រលប់ទៅវិញ។ ពេលនាងចេញពីមាត់ក្របីព្រៃ ក៏ទៅជួបនឹងដំរីមួយហ្វូងទៀត ហើយក៏ធ្វើរបៀបដូចមុនទៀត។ ម្ដងនេះត្មាតមកមួយទ័ពធំ ហើយគ្នាដំរីក៏មានមួយទ័ពធំដែរ។ ត្មាតក្ដុំពីដើមធំណាស់គ្រាន់តែវាទទះស្លាបមួយក៏ប ខ្យល់បក់រំភើយរាប់យោជន៍ឯណោះ មិនមែនដូចត្មាតឥឡូវស៊ីខ្មោកពាល់ថ្ងៃ

ហ្នឹងទេ។ ទ័ពដំរីនិងទ័ពត្មាតប្រយុទ្ធគ្នាយ៉ាងសន្ធឹកឡើងខ្ទេចរិច ឆាប់អស់ព្រៃ។ ដល់ទ័ពទាំងពីរប្រយុទ្ធគ្នាយូរៗទៅ ក៏មានរបួសរៀងៗខ្លួនអាត្មាតក៏មានរបួស ដំរីក៏មានរបួសដែរ តែទ័ពត្មាតមានរបួសនិងស្លាប់ច្រើនជាងទ័ពដំរី ស្ដេចត្មាតខឹងនឹងដំរីខ្លាំងណាស់ក៏ហោះត្រលប់ទៅកន្លែងវាវិញ ហើយសំកាំងលើមេឃធ្វើដូចពពកបាំងព្រះអាទិត្យអញ្ចឹង។ អញ្ចឹងដំរីក៏ខ្លាក់នាងជាកូនសេដ្ឋីចេញមក ហើយផ្ដាំនាងថា៖ "ឥឡូវនាងឯងទៅខាងមុខបន្តិចទៀតនឹងជួបអាស្រមមុនីឥសីហើយ! អាស្រមព្រះមុនីអគ្គិនេត្រហើយ! លោកនឹងជួយយកអាសារនាង!"

នាងឮហើយ ក៏ប្រញាប់ចេញដំណើរទៅមុខទៀត ក៏ទៅជួបនឹងអ្នកបម្រើព្រះមុនីឥសីឈ្មោះអាគាំងកំពុងតែដើរកាច់ផ្កាឈើដើម្បីយកទៅឲ្យព្រះមុនីឥសីលោកដើរសន្ត្រំភាវនាធម៌។ អាគាំងរវល់តែបេះផ្លែឈើព្រៃ នាងនោះក៏រត់ទៅជាប់នឹងព្រំសីមាព្រះមុនីឥសី ព្រះមុនីអគ្គិនេត្រក្រឡេកទៅឆេះនាងភឹប។ ពេលនោះស្ដេចត្មាតក៏មកតាមទាន់នាងនោះដល់ព្រំសីមាព្រះមុនីឥសីដែរ ហើយក៏មានការប្រយុទ្ធគ្នាជាមួយហ្វូងស្ដេចត្មាត ប៉ុន្តែព្រះមុនីឥសីអគ្គិនេត្រគ្រាន់តែក្រឡេកភ្លាម ក៏ឆេះហ្វូងត្មាតស្លាប់អស់ទៅ។ ហើយព្រះមុនីឥសីនាំនាងទៅក្នុងអាស្រមរបស់លោកដើម្បីជួយសង្គ្រោះ ជប់ប្រោសនាងហ្នឹងឡើងឲ្យរស់នឹងបានល្អដូចដើមវិញ។ ដូច្នេះលោកក៏យកនាងទៅដាក់បន្ទំជារូបចម្លាក់ជាមួយនឹងរូបព្រះបដិមាករ គឺល្អដូចគ្នាទាំងអស់គ្មាននរណាអាចដឹងបានទេនៅក្នុងអាស្រមទិសខាងលិចនៃកុដិរបស់លោក ហើយហាមអាគាំងនិងសត្វចិញ្ចឹមបក្សាបក្សីទាំងអស់ដូចជាកុក ក្រសារ ក្អែក ស្មោញ ត្រដក់ ដាច់ខាតមិនឲ្យទៅទិសខាងលិចនោះទេ ។

និយាយពីរឿងកូនស្ដេចមួយអង្គ បានលាព្រះបិតាចេញមកស្វែងរៀនសិល្ប៍វិជ្ជាការ មន្តអាគមគាថានៅតាមព្រឹក្សាធំៗ។ លាព្រះបិតាព្រះមាតាចេញមកដល់ក្នុងព្រៃហើយ ក៏ដើរទៅជួបនឹងអាស្រមព្រះមុនីឥសី។ ព្រះ

មុនីឥសីក្រឡេកទៅឃើញក៏ធេះ រលាយរូបកូនស្ដេចអស់ ហើយលោកក៏ជប់ប្រោសឲ្យរស់ពានមានជីវិតឡើងវិញតាមបំណងប៉ងប្រាថ្នា។ ហើយលោកក៏ឲ្យរៀនមន្តអាគមវិជ្ជាការចេះសព្វបែបយ៉ាង។ រាជកុមារក៏នឹកចង់ទៅលេងកំសាន្តព្រៃលេង ក៏បបួលអាគាំងដើរលេងជាមួយ ហើយចេះតែលួងលោមអាគាំងសួរថា៖ "បងគាំង! ម៉េចបានជាព្រះមុនីឥសីលោកមិនឲ្យទៅលេងនៅសាលាទិសខាងលិច វាមានរឿងហេតុកេទយ៉ាងណា?"

អាគាំងថា៖ "ខ្ញុំមិនហ៊ានប្រាប់ទេ បើកាលណាទៅហើយលោកតាដឹងថាប្រាប់អំពីរឿងសាលាទិសខាងលិចហ្នឹង លោកនឹងរំលាយខ្ញុំឲ្យបាត់បង់រូបឆោមលោមពណ៌ខ្ញុំជាអាគាំងហើយ! ខ្ញុំមិនហ៊ានប្រាប់ទេ!"

ដល់អញ្ចឹងអាគាំងមិនហ៊ានប្រាប់ទេ។ ប៉ុន្តែនិយាយពីកុក ក្រសារ អានាលត្រដក់អីសព្វគ្រប់បែបយ៉ាងទាំងអស់ និងស្វាមួយទៀត បានកូនស្ដេចលួងលោមឲ្យផ្លែឈើឲ្យចំណីរអីស៊ីទៅក៏មានចិត្តទន់ប្រាប់។

កូនស្ដេចសួរថា៖ "អាណាហ៊ានប្រាប់អញថារបស់អ្វីដែលនៅសាលាខាងលិចហ្នឹងបានជាឥសីមិនឲ្យទៅ តើវាមានរបស់អីសំខាន់?"

ដំបូងសត្វទាំងអស់ក៏មិនហ៊ានដែរ មានតែត្រដក់មួយទេ ដែលហ៊ានប្រាប់។ សត្វត្រដក់ថា៖ "ឲ្យតែលោកម្ចាស់ឲ្យចំណីអ្វីៗទាំងឡាយដល់ខ្ញុំស៊ីចុកបុកទំពារបានឆ្អែតរាល់ថ្ងៃហ្នឹងខ្ញុំនឹងប្រាប់ការពិតចំពោះលោកម្ចាស់!"

រាជកុមារសន្យាថា៖ "ឲ្យតែប្រាប់យើង យើងនឹងឲ្យចំណីចំណុកជាទីពេញចិត្តដល់បងត្រដក់ឯង!"

ត្រដក់ក៏លួចខ្សឹបប្រាប់ថា៖ "នៅសាលាទិសឯលិចនេះមានបុត្រីម្នាក់ល្អណាស់ លោកម្ចាស់! ល្អណាស់ បើកាលណាព្រះអង្គយាងទៅមិនដឹងរបៀប ក៏មិនអាចមើលស្គាល់ថានាងជាមនុស្សដែរ! បើធ្វើតាមខ្ញុំ អាហ្នឹងអាចដឹង!"

រាជកុមារសួរថា៖ "ធ្វើម៉េច?"

ត្រដក់និយាយថា៖ "ព្រះអង្គពេលស្ងាត់ យាងទៅហើយយកចង្កៀលដៃហ្នឹងទៅស៊កជ្រ ល ភ្នែក បើភ្នែកមនុស្សជ្រ ល ទៅជិតដល់ហ្នឹងពព្រិចហើយ នោះជាមនុស្ស អើបើកាលណាថ្មវាមិនពព្រិចទេ ពីព្រោះរូបទាំងពីរនោះដូចគ្នា!ៗ"

ដល់អញ្ចឹង កូនស្ដេចក៏ចាំរាល់ពាក្យផ្ដាំរបស់ត្រដក់ ហើយក៏លបចូលទៅសាលាទិសខាងលិចមែនៗ ពេលចូលទៅ រាជកុមារក៏ចង្កៀលតាមពាក្យត្រដក់ ដឹងថានេះជាមនុស្សពិតប្រាកដមែន ហើយល្អស្អាតទៀត ក៏ចាប់ចិត្តផ្ដោះផ្ដងសារសេងស្នេហាក្បត់បណ្ដាំឥសីៗ ដល់រឿងនោះបែកការណ៍ ដឹងដល់ឥសី ឥសីក៏ចាប់អាគាំងនិងហៅសត្វទាំងអស់មកសួរៗ ពេលសួរទៅ មួយថាមិនដឹង ពីរថាមិនដឹងៗ ក្នុងចំណោមសត្វទាំងនោះមានតែសត្វត្រដក់ទេដែលមានមាឌធំជាងគេ ហើយមើលទៅព្រះមុនីឥសីសង្ស័យក៏ចាប់ឈ្លេចសួរៗ

អាត្រដក់ថា៖ "បាទមែន! ខ្ញុំលោកតា ខ្ញុំឃ្លានចំណីអាហារពេក!"

តាឥសីបញ្ជាថា៖ "បើអញ្ចឹងហ្អែងមកនេះ! ចូលមកឲ្យជិតកាលណាកាន់តែល្អ!"

លោកតាឥសីចាប់បោចសក់ត្រដក់ឲ្យអស់ពីក្បាល កុំឲ្យដុះតពូជតពង្សហ្អែងតទៅមុខទៀតៗ តាឥសីធ្វើទារុណកម្មធ្វើបាបសត្វត្រដក់នេះៗ រួចកូនសេដ្ឋីនិងកូនស្ដេចព្រះមុនីឥសីហៅមកផ្សំផ្គុំគ្នាទៅ ព្រោះជាគូព្រេងពីអតីតជាតិៗ កូនស្ដេចហ្នឹងបានថ្វាយបង្គំលាព្រះមុនីឥសីត្រលប់ទៅព្រះនគរខ្លួនវិញៗ អញ្ចឹងហើយបានជាសត្វត្រដក់មិនដុះសក់លើក្បាលតរហូតមកៗ៕

# ១៥- រឿងតាដុងយាយជ័យ

**និទានដោយយាយហួន** [22]

លោកយាយហួនមានអាយុជាង៧០ឆ្នាំ គាត់មានស្រុកកំណើតនៅស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។ គាត់បាននិទាន**រឿងតាដុងយាយជ័យ** ប្រាប់ដល់ក្រុមអ្នកប្រមូលរឿងព្រេងខ្មែរយើងខ្ញុំ។ គាត់បានមានប្រសាសន៍ថា៖ គាត់បានកើតទាន់ផ្ទះតាដុងយាយជ័យដែលនៅសល់ផ្ទោងនិងផ្ទានប្រមាណ៥តឹក។ កាលគាត់មានអាយុ១២ឆ្នាំ គាត់បានទៅស្រែប្រាំងជាមួយឪពុកគាត់ ហើយឪពុកគាត់បានប្រាប់គាត់ថា នេះជាផ្ទះរបស់តាដុងយាយជ័យ។

គាត់ក៏បាននិទានរឿងតាដុងយាយជ័យដែលមានដំណើររឿងដូចតទៅ៖

យាយជ័យមានអាយុ៤០ឆ្នាំ តែគាត់អត់មានកូនទេ។ ថ្ងៃមួយ គាត់សុបិន្តនិមិត្តឃើញរើសបានចិញ្ចៀនព្រះទំរង់មួយវង់។ គាត់ក៏បាននិយាយរឿងសុបិន្តនេះប្រាប់តាដុង។

តាដុងនិយាយថា៖ "ខ្ញុំមិនចេះកាត់សុបិន្តនេះទេ បើអញ្ចឹងយើងគួរធ្វើបាយសម្លទៅវត្តប្រគេនលោកតា ដើម្បីឲ្យលោកតាជួយកាត់សប្តិឲ្យ!"

យាយជ័យ ក៏ធ្វើបានបាយសម្លទៅប្រគេនលោកតា។ តាយាយក៏បានរៀបរាប់ប្រាប់ពីសុបិន្តរបស់គាត់ដល់លោកតា។ ក្រោយពីបានស្តាប់ហើយ លោកតាមានសង្ឃដីការថា៖ "ញោមទាំងពីរនឹងមានបុត្រហើយ។"

តាដុងពេលដែលដឹងថាប្រពន្ធជិតមានបុត្រដូច្នេះ តែងតែថ្នាក់ថ្នមយាយមិនឲ្យដងទឹកមិនឲ្យពុះអុសទេ

---

22 ភូមិឃ្លាំងប្រាំ ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។

ព្រោះខ្លាចអត់កូនៗ ដល់យូរៗទៅ យាយជ័យក៏មានផ្ទៃពោះៗ យាយក៏ប្រសូតបានកូនស្រីមួយដែលគួរឲ្យស្រលាញ់ៗ ហេតុតែម្ដាយស្រលាញ់កូនពេក យាយក៏ដាក់ឈ្មោះកូនថា **នាងកញ្ចាលដោះក្រាល** ហើយយាយតាខំបីបាច់ចិញ្ចឹមកូនបានធំធាត់ពេញរូបរាងៗ

តាដុងយាយជ័យមានពួកម៉ាក់ម្នាក់ឈ្មោះ **តាព្រានព្រៃធានវឹង** រស់នៅភូមិព្រៃននោងខាងត្បូងៗ តាធានវឹងនេះជាអ្នកបម្រើស្ដេចសោយរាជ្យនៅលង្វែកៗ ថ្ងៃមួយ តាធានវឹង ស្ដេចនិងព្រះមហេសីដែលមានផ្ទៃពោះជិតគ្រប់ខែបានទៅក្រសាលព្រៃមួយៗ ដោយព្រះស្វាមីមិនដឹងថាព្រះមហេសីជិតគ្រប់ខែទេ ពេលដែលកំពុងតែយាងកំសាន្តព្រះមហេសីក៏ទៅខ្សឹបប្រាប់ព្រះស្វាមីថា៖ "ព្រះអង្គខ្ញុំម្ចាស់ឈឺពោះហើយ!"

ស្ដេចឮដូច្នេះ ក៏នាំព្រះមហេសីចូលព្រៃទៅប្រសូត្រមកបានកូនជាពងទំហំប៉ុនផ្លែឪឡឹកៗ ដោយខ្មាស់គេពេក មិនហ៊ានយកពងនេះចូលទៅក្នុងរាជវាំង ក៏លួចកាយកប់ចោលនៅក្នុងព្រៃ ហើយក៏នាំមហេសីមកវាំងនៅបន្ទាយលង្វែកវិញៗ ពេលជិតដល់ថ្ងៃចូលឆ្នាំថ្មី តាដុងយាយជ័យក៏នាំនាងកញ្ចាលដោះក្រាលអាយុ១៥ឆ្នាំ ទៅលេងប្អូនយាយជ័យឈ្មោះ**យាយទឹម**ៗ ពេលដើរកាត់ទៅក៏ទៅជួបតាធានវឹងនៅកណ្ដាលព្រៃៗ

តាធានវឹងសួរ៖ "អូ! តាដុងទៅណា? "

តាដុងតប៖"ទៅផ្ទះប្អូន! ហើយចុះវឹងឯងរកអ្វី?

តាវឹងថា៖ "អេនាំកូនហាត់គុណដាវ គុណដំបង!"

តាធានវឹងនិងតាដុងយាយជ័យក៏និយាយចរចារសួរនាំគ្នាលេង៣នាក់ហ្នឹងទៅៗ នាងនោះអន្ទុយម្នាងហើយកូននាយប្រមាញ់ធានវឹងអន្ទុយម្នាងៗ ចេះតែនាំគ្នាស្ដាប់ឪពុកម្ដាយស្ដីដណ្ដឹងនាងហ្នឹងៗ ដល់ស្ដីដណ្ដឹង

ហើយ ថ្ងៃល្ងាចក៏គិតលាគ្នាទៅ។ ទៅដល់ផ្ទះយាយទឹម តាដុងយាយជ័យប្រាប់ប្អូនថា៖ "បើសិនជាបានវីងមកលេងផ្ទះអី ឲ្យទទួលស្គាល់គ្នាជាញាតិជាមិត្តទៅ ព្រោះអីអញបានលើកកូនទៅឲ្យកូនវាហើយ។"

តាដុងយាយជ័យមកលេងបានពីរបីថ្ងៃហើយ គាត់ត្រូវត្រឡប់មកផ្ទះវិញ។ យាយទឹមនិយាយថា៖ "បងប្រញាប់យកមីនាងទៅធ្វើអី ទុកវានៅលេងទីនេះសិនទៅ ចាំចូលឆ្នាំរួច សឹមមកយកនាងត្រលប់ទៅផ្ទះវិញ។"

តាដុងគក៏ឲ្យកូនស្រីនៅទីហ្នឹង រួចក៏ត្រលប់មកផ្ទះតែពីរនាក់ប្ដីប្រពន្ធ។ ពេលដល់ថ្ងៃចូលឆ្នាំរួច តាដុងក៏ទៅយកកូនមកផ្ទះវិញ។ នាងកញ្ចាលដោះប្រាលទឹកថា៖ "អញកាលមកនៅផ្ទះមីងនៅព្រៃនោងបានឃើញកូនប្រុសនាយប្រមាញ់រាល់ថ្ងៃ តែដល់ពេលមកផ្ទះអញវិញ ដូចជាទឹកគេខ្វាំងណាស់។"

គិតហើយនាងក៏លួចរត់ចញពីផ្ទះបំណាងទៅជួបគូរដណ្ដឹង។ នាងលបរត់រហូតដល់ដំបូកមួយ។ គាប់ជួនស្ដេចដែលគ្មានកូន និងព្រាហណ៍បុរោហិត២នាក់កំពុងតែជិះសេះកំសាន្តលេងព្រៃ។ ដល់អញ្ចឹងទៅក៏ឃើញនាងកញ្ចាលដោះប្រាល ព្រះអង្គក៏និយាយថា៖ "យី! មកពីណាមក អីក៏ល្អម្ល៉េះ!"

ព្រះអង្គបញ្ជាឲ្យសេនាដេញចាប់នាង។ ដេញចុះដេញឡើង។ រហូតដល់ខ្វេចព្រៃអស់។ នាងកញ្ចាលដោះក្រាលបានឃើញរន្ធដំបូកនាងក៏និយាយខ្សឹបៗថា៖ "អឺ! សុំលាក់ខ្លួនផងគេដេញចាប់ខ្ញុំហើយ!"

នាងក៏ចូលរន្ធដំបូកនោះលាក់ខ្លួនជិតបាត់ទៅ ទើបបានជាជាប់ឈ្មោះថា**ដំបូកមានលាក់**អញ្ចឹងរហូតមក។ ស្ដេចនិងបរិវារទំរកហើយនៅតែរកមិនឃើញ រកហើយរកទៀតនៅតែមិនឃើញ រហូតដល់ពេលល្ងាចហើយព្រះអង្គក៏នាំគ្នាត្រឡប់មកវាំងវិញ។ ឯនាងនោះក៏អត់រត់ទៅណាដែរ ព្រោះងងឹតហើយក៏មកផ្ទះវិញ។ ឯឪពុកក៏មិនដឹងថាកូនមានបំណាងពន្រត់គ្នាដែរ។ ស្ដេចតាំងពីឃើញនាងហ្នឹងមក ក៏គិតថាធ្វើយ៉ាងម៉េច ឲ្យបានជួបនាង

ម្ដងទៀតៗ ដល់ពេលចុះទូកផែកំពង់ហ្លួង ស្ដេចបានឲ្យព្រាហណ៍បុរោហិតទាំងអស់ក្លែងជារាស្ត្រដើម្បីដើរទៅគន់មើល បើឃើញនាងហ្នឹងហើយត្រូវតាមដានឲ្យដឹងថាតើនាងនៅភូមិណា? ស្រុកណា?

ពេលពួកព្រាហ្មណ៍ដើរមកដល់កន្លែងគេអុំទូក តាដុងយាយជ័យក៏បាននាំកូនស្រីគាត់ទៅមើលគេអុំទូកនៅកំពង់ហ្លួងដែរៗ លុះដល់ពេលគាត់ត្រលប់មកផ្ទះវិញ មានពួកព្រាហ្មណ៍ដើរតាមគាត់រហូតស្គាល់ផ្ទះដែលឋិតនៅខាងត្បូងវត្តទេពប្រណម្យហ្នឹងៗ ពេលបានដំណឹងថានាងរស់នៅកន្លែងណាហើយ ព្រាហ្មណ៍បុរោហិតក៏យកដំណឹងនេះទៅទូលស្ដេចថា៖ "ផ្ទះនាងនៅខាងត្បូងវត្តទេពប្រណមនេះទេ!"

ស្ដេចបានឲ្យគេលើកអាករសេរីទៅស្ដីដណ្ដឹងនាងកញ្ចាលដោះក្រាល តែតាដុងនិយាយថា៖"កូនខ្ញុំមានប្ដីហើយ! ខ្ញុំមិនលើកឲ្យទេ ព្រោះកូនស្រីខ្ញុំបានលើកឲ្យគេហើយៗ"

ស្ដេចបន្ទូលថា៖ "មិនអាចលើកឲ្យនរណាបានទេ ត្រូវតែលើកនាងមកឲ្យព្រះអង្គៗ"

តាដុងគាត់មានអំណាចដែរ តែគាត់ប្រកែកមិនបានធ្វើអីក៏មិនបានទៀត តែនិយាយថា៖ "បើធ្វើដូច្នេះគាត់នឹងថ្វាយកូនស្រីទៅឲ្យបាន លុះណាតែព្រះអង្គលើកថ្នល់ពីវាំងមកដល់ផ្ទះខ្ញុំតែមួយយប់ បើកាលណាមិនដល់ទេ ភ្លឺត្រឹមណាឲ្យចុះវារត្រឹមហ្នឹងមក!"

ឮដូច្នេះស្ដេចក៏កេណ្ឌពលរេហ៍និងមនុស្សម្នាទាំងអស់ឲ្យមកធ្វើថ្នល់ទាំងយប់ៗ មកដល់មាត់ស្ទឹងកំពង់វិហារ មេឃក៏ភ្លឺឡើងៗ ស្ដេចក៏ចុះវារមកៗ តាដុងដឹងដំណឹងថាស្ដេចលើកផ្លូវមកដល់យប់ហ្នឹង ហើយតាដុងក៏ឲ្យយាយជ័យនាំកូនទៅប្រាប់ព្រានវីងឲ្យឆាប់រៀបការកូនក្នុងពេលឥឡូវហ្នឹងភ្លាម ព្រោះស្ដេចប្រុងដណ្ដើមយកកូនស្រីហើយ ព្រានវីងក៏រៀបការនៅព្រៃនោងហ្នឹងទៅៗ ស្ដេចវារមកដល់វត្តទេពប្រណមហ្នឹង ក៏អន្ដុយ

លុតជន្លង់ប្រណាមនៅទីនោះចាំឲ្យនាងហ្នឹងមកទទួល។ តាដុងដឹងថាគេលើកមកដល់គេកំពុងប្រណាមអញ្ចឹងក៏យណាស់ក៏រត់ទៅដល់ភ្នំទសពិជ។ ប៉ុន្តែគាត់បានវង្វេងរកផ្លូវទៅព្រៃនទោងមិនឃើញ។

រីឯស្ដេចលុតជន្លង់អង្គុយប្រណាមហ្នឹង ចាំយូរពេកមិនឃើញមានអ្នកចុះមកទទួលសោះ ក៏ចាត់ឲ្យពួកសេនាម៉ឺនសព្វមុខមន្ត្រីទៅមើលថាតើពួកគេទៅឯណាអស់ហើយ ហេតុអីបានជាមិនឃើញចុះមកជួបព្រះអង្គ? ពេលពួកនាម៉ឺនទៅមើលទៅឃើញផ្ទះទទេ អត់មានអ្នកណានៅម្នាក់។

ពួកនាម៉ឺននិយាយថា៖ "អុញ រត់បាត់អស់ហើយ!"

ស្ដេចខឹងណាស់ក៏សួរថា៖ "តើគេមានបងប្អូនញាតិសន្ដានកន្លែងណា?"

ព្រាហ្មណ៍បុរោហិតនិយាយថា៖ "អូ! ពួកគេមានបងប្អូននៅព្រៃនទោងខាងត្បូង!"

ស្ដេចមានព្រះតម្រិះថា៖ "បើអញ្ចឹងពួកគេពិតជានាំគ្នារត់ទៅហ្នឹងហើយ!"

ស្ដេចក៏ត្រលប់ទៅវាំងវិញ ហើយទៅនាំពួកនាម៉ឺនមន្ត្រីទាំងអស់ជិះសេះទៅតាមរកគ្រួសារតាដុងយាយជ័យនៅព្រៃនទោង។

និយាយពីតាដុងវិញ។ គាត់រត់ៗទៅក៏វង្វេងផ្លូវបានទៅដល់ភ្នំទសពិជ ហើយក៏បានជួបក្មេងឃ្វាលគោសួរថា៖ "ឯណាផ្លូវទៅព្រៃនទោង?"

អាក្មេងចង់ស៊ីសំណែនផង ក៏និយាយថា៖ "តាឯងខុសអ្នកតាព្រៃភ្នំហើយបានជារកផ្លូវមិនឃើញដូច្នេះអញ្ចឹងទាល់តែតាឯងសែនជ្រូកទឹមទាទឹម ជ្រូកខ្វៃស្អីសព្វគ្រប់ទាំងអស់ តាឯងនឹងអាចរកផ្លូវទៅព្រៃនទោងឃើញហើយ។"

តាជុងគាត់អត់លុយគាត់ក៏សុំអ្នកស្រុកធ្វើឲ្យគាត់សិន គេក៏រៀបសែនព្រេនទៅ។ សែនរួចទើបក្មេងនោះថា៖ "អើ! តាឯងដើរតាមផ្លូវហ្នឹងទៅដល់ព្រៃននោងហើយ!

កូនក្មេងឃ្វាលគោក៏ស៊ីសំណែនហ្នឹងអស់ទៅ។ រីឯ កូនកំលោះក្រមុំកំពុងតែសំពះផ្ទឹមនៅឡើយ ហើយពេលតាជុងទៅដល់ ស្ដេចនាម៉ឺនសព្វមុខមន្ត្រីក៏ទៅដល់។ ស្ដេចលោតពីលើសេះមក ហូតព្រះខ័នខ្វាក បម្រុងវាសកាប់តែម្ដង តែតាជានវីងស្រែកថា៖ "កុំកាប់ នេះជាកូនប្រុសទូលព្រះបង្គំទេ!" តាជានវីងក៏ទៅឱបព្រះបាទាស្ដេច។

ដល់អញ្ចឹងទៅ ស្ដេចក៏សួរថា៖ "ចុះវីងឯងមានប្រពន្ធឯណាបានជាមានកូនហ្នឹង? ឯងបានកូនពីណា?"

ក្រាបទូល ចាំទូលបង្គំទូលព្រះអង្គឲ្យទ្រង់បានជ្រាប៖ "កូនហ្នឹងទូលបង្គំរើសបានកាលទូលបង្គំបានទៅបរបាញ់សត្វនៅក្នុងព្រៃទេ ទូលបង្គំមានឆ្កែ៥ តែមានឆ្កែមួយឈ្មោះមីអង្គ្រែងហ្នឹង វាវៀសជាងគេ វាគាស់កាយៗ កាយហិតៗទៅ ទូលបង្គំសង្ស័យក៏កាយតាមឃើញពងមួយប៉ុនឪឡឹកកប់នៅក្នុងព្រៃ។ ទូលបង្គំក៏យកពងនោះមករក្សាទុកបាន៧ថ្ងៃ ក៏ស្រាប់តែកើតញាស់ចេញកូនមនុស្សនេះឯង។"

ស្ដេចសួរថា៖ "ព្រៃមួយណា?"

តាជានវីងក៏និយាយប្រាប់ពីព្រៃនោះទៅ។ ស្ដេចក៏ដឹងថាជាកូនខ្លួនដែលយកទៅកប់ចោល ក៏ចេញបញ្ជា៖ "តោះងើបឡើងៗកូនទាំងពីរគួរទៅរៀបអភិសេកនៅឯក្នុងវាំងវិញ!"

អ្នកទាំងពីរនិងក្រុមគ្រួសារទាំងអស់គ្នាក៏ទៅរៀបអភិសេកនៅបន្ទាយលង្វែកហ្នឹងទៅ៕

# ១៦- ទន្សាយព្រះពោធិសត្វ

## និទានដោយ ព្រះតេជគុណ ម៉ោ ម៉េង[23]



23 លោកគង់នៅវត្តខ្នារ ភូមិខ្នារ ឃុំស្នាមព្រះ ស្រុកបាកាណ ខេត្តពោធិ៍សាត់។

តើវត្តព្រែកស្ដីហ្នឹង មានធ្វើបុណ្យអកអំបុកទេលោកតា?

ធ្វើតើ ធ្វើរៀងរាល់ឆ្នាំ!

មានរឿងរ៉ាវយ៉ាងម៉េចដែរតេជគុណ បានជាយើងធ្វើបុណ្យនេះ?

មានរឿងនិយាយថា កាលនោះព្រះអង្គទ្រង់យោនយកកំណើតជាសត្វទន្សាយ។ ព្រះអង្គចង់បូជាជីវិតដើម្បីធ្វើទានកសាងចិត្តឲ្យជ្រះថ្លា ប៉ុន្តែពុំមានអ្នកត្រូវទទួលទានពីលោកសោះ។ ដូច្នេះហើយ ការតាំងប្រាថ្នាឧទ្ទិសនេះបានក្ដៅទៅដល់អសនៈរបស់ស្ដេចនៃទេវតាគឺព្រះឥន្ទ្រ។

ព្រះឥន្ទ្រឈ្ងល់ថា៖ "អសនៈរបស់ព្រះឥន្ទ្រដែលធ្លាប់តែត្រជាក់ដូចថ្ម ដេករាល់ថ្ងៃមិនចង់ងើប ស្រាប់តែថ្ងៃនេះចុះចម្លែកអីក្ដៅម្ល៉េះ! ប្រហែលជាឋានកណ្ដាលមានបញ្ហាអីកើតហើយមើលទៅ!"

អញ្ចឹងព្រះឥន្ទ្រក៏បើកទិព្វចក្ខុមើល ក៏ឃើញការតាំងប្រាថ្នារបស់ព្រះពោធិសត្វដែលសុខចិត្តបរិច្ចាកអ្វីៗទាំងអស់។ ពេលនោះ ព្រះឥន្ទ្រក៏ទៅតាំងំណែងខ្លួនជាព្រាហ្មណ៍ចាស់ម្នាក់ដើរមករកទន្សាយសហ្នឹង តែធ្វើជាមិនឃើញ មិនដឹង មិនឮទន្សាយសនោះទេ ហើយពោលវាចាថា៖ "ខ្ញុំបាទអត់អាហារហ្នឹងច្រើនថ្ងៃមកហើយ អញ្ចឹងថ្ងៃនេះមុខជាស្លាប់ហើយ បើសិនជាមិនមានអ្វីបរិភោគទេ!"

ឮដូច្នេះ ទន្សាយដែលមានបំណងចង់បូជាជីវិតនោះមានចិត្តអាណិតដល់ឥន្ទព្រាហ្មណ៍ចំណាស់ផង ក៏ចេញមកខាងហើយសួរថា៖ "តើតាឯងអត់បាយប៉ុន្មានថ្ងៃហើយតា?"

ព្រាហ្មណ៍នោះថា៖ "ច្រើនថ្ងៃហើយ អត់មានអាហារបរិភោគទេ!"

ទន្សាយថា៖ "បើអ្នកឯងឃ្លានអញ្ចឹង មិនចាំបាច់ពិបាកចិត្តទេ ឥឡូវយើងសុខចិត្តបូជាជីវិត ឲ្យតែអ្នកឯង

បានរស់ យើងសុខចិត្តស្លាប់! ឥឡូវចូរអ្នកឯងយកឧសមកគរបង្កាត់ភ្លើងទៅ ខ្ញុំនឹងទៅលាងខ្លួនសិន ពេលលាងរួចហើយ ខ្ញុំនឹងលោតចូលភ្លើងដើម្បីឲ្យអ្នកឯងយកសាច់ខ្ញុំបរិភោគជាអាហារចុះ!"

ទន្សាយពោធិសត្វក៏ទៅលាងខ្លួនយ៉ាងស្អាតៗ ដល់ពេលលាងខ្លួនស្អាតហើយ ឥន្ទព្រាហ្មណ៍ហ្នឹងមិនពិបាកទៅរកឧសឯណាទេព្រោះគាត់ជាព្រះឥន្ទ្រទៅហើយៗ អញ្ចឹងគាត់គ្រាន់តែប្រើវេទមន្តឫទ្ធិឥទ្ធិពលរបស់គាត់បន្តិចទៅ ក៏សំរេចទៅជាគ្នក់ភ្លើងមួយយ៉ាងធំឆេះនៅកន្លែងហ្នឹងៗ

ពេលទន្សាយពោធិសត្វមកដល់ ក៏លោតចូលភ្លាមៗ លុះលោតហើយ ក៏មានអានុភាពអព្ភូតហេតុមួយកើតឡើងចំពោះទន្សាយ ព្រោះជាធម្មតាអ្នកលោតចូលទៅក្នុងភ្លើង ហើយអ្នកណាដែលថាមិនរលាក មនុស្សធម្មតាក៏ដោយ សត្វតិរិច្ឆានក៏ដោយចូលភ្លើងត្រូវតែរលាក តែចម្លែកទន្សាយហ្នឹងអត់ស្លាប់ទេ ដោយអំណាចបារមីដែលសន្សំមកតាំងពីដើម ហើយជ្រះថ្លាចំពោះប្រយោជន៍សាធារណៈអាចរួចផុតទុក្ខផុតទោសពីភ្លើងហ្នឹងបានសូម្បីតែរោមមួយក៏មិនឆេះផង ឯភ្លើងដែលកំពុងឆេះសន្ធោសន្ធៅនោះបែរជាត្រជាក់ៗ ដល់ពេលអញ្ចឹងទៅព្រះឥន្ទ្រក៏នាំយកកាពអស្ចារ្យទៅឋានលើទុកជាកស្តុតាងៗ មិនដឹងយកទុកកន្លែងណាឲ្យសមគួរគឺមានតែទុកនៅកន្លែងព្រះខែហ្នឹងឯង ព្រោះថាពេលយប់ព្រះខែមានពន្លឺអាចឲ្យគេមើលឃើញច្បាស់ អញ្ចឹងព្រះឥន្ទ្រក៏យកដុំថ្មទៅគូសនៅនឹងវង់ព្រះខែជារូបមានដូចជា ដើមពោធិព្រឹក្សដែលតំណាងឲ្យការត្រាស់ដឹងនៅកន្លែងរបស់ព្រះឥន្ទ្រ និងឃើញរូបសត្វទន្សាយសក្នុងកាលបរិច្ចាគទានបរិច្ចាគជីវិតដើម្បីឥន្ទព្រាហ្មណ៍នៅក្នុងព្រះខែនោះដែរៗ

ប្រជាជនខ្មែរដែលកាន់ព្រះពុទ្ធសាសនាទាំងអស់គ្នា តែងតែគោរពធ្វើបុណ្យអកអំបុក សំពះព្រះខែទូ

ទាំងប្រទេស ក្នុងពិធីថ្ងៃពេញបូរមីខែកត្តិកជាថ្ងៃមួយដ៏នក្ខត្តឫក្សល្អដើម្បីរំលឹកគុណដល់ព្រះសម្មាសម្ពុទ្ធយើងកាលកើតជាសត្វទន្សាយបូជាជីវិតដើម្បីប្ដូរយកការត្រាស់ដឹងរបស់ខ្លួន។ ដូច្នេះ គេប្រារព្ធពិធីនេះឡើងដើម្បីរំលឹកដល់ព្រះតាមដំណើររឿងខាងលើនេះឯង ។

តាមចំណាំ ពេលមើលព្រះខែនៅថ្ងៃពេញបូរមី យើងប្រាកដជាឃើញអាការៈដូចជាសត្វទន្សាយនៅក្នុងហ្នឹងមែន ឯអ្នកខ្លះទៀតមើលទៅឃើញស្នាមពន្លឺក្រហមៗដែលចែងចាំងនៅក្នុងព្រះខែនោះ គេបែរជាយល់ថាជារូបយាយជីបុកអង្ករអើទៅវិញ។ នេះជារឿងដែលឲ្យនិយមន័យ ទៅតាមការយល់ឃើញនិងតាមការតំណាលតៗមករបស់ចាស់បុរាណ៕

# ១៧- រឿងភ្នាក់ដៃ (ផ្លែឈើ៣៦មុខ)

## និទានដោយលោកតា ឆាយ កង [24]



24 នៅភូមិអង្គតាចន្ទ័ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

រឿងភ្នាក់ដៃហ្នឹងគេនិយាយអញ្ចេះៗ និយាយពីមាណពពីរនាក់ប្រពន្ធមានកូនខ្ចីម្នាក់ៗ ថ្ងៃមួយនោះគាត់ពរកូនគាត់ហើយនាំគ្នាទៅងូតទឹកនៅស្ទឹងមួយៗ កូនោះវានៅខ្ចីណាស់អាយុប្រហែលបីបួនប្រាំខែប៉ុណ្ណោះៗ លុះងូតទឹកឲ្យកូនរួចហើយ គាត់ក៏យកកូនមកដាក់លើកន្ទបដែលក្រាលនៅឯមាត់ទឹកៗ ដាក់កូនលើកំណាត់កន្ទបរួចហើយ ទាំងពីរនាក់ប្ដីប្រពន្ធចុះមុជទឹកទៅៗ កំពុងតែមុជទឹក និយាយអំពីសត្វវាយុភក្ស [25]ដើរហើរស្វែងរកចំណីនៅលើអាកាសៗ ពេលហើរមកដល់ វាសម្លឹងពីលើមកឃើញក្មេងនៅក្បែរមាត់ទឹក គិតស្មានតែដុំសាច់ វាក៏បោះពួយវ៉ើរមកដល់ធក់យកកូននោះទៅលើអាកាសបាត់ទៅៗ

ដល់សត្វវាយុភក្សប្រុងនឹងយកចំពុះមកចឹកស៊ីសាច់នោះ វាឮសម្លេងយំផាំៗ បានសត្វនោះនឹកគិតថា៖ "យី នេះជាមនុស្សតើ! បើអញ្ចឹងអញយកវាទៅចិញ្ចឹមជាកូនជាចៅចុះ!"

លុះដល់កូននោះអាយុ១០-១៥ឆ្នាំអញ្ចឹងទៅ កូននោះសួរទៅសត្វវាយុភក្សថា៖ "តើម៉ែឪខ្ញុំជាមនុស្ស ឬឪនិងម៉ែជាសត្វ? ខ្ញុំឆ្ងល់ណាស់ខ្ញុំមិនអស់ចិត្តទេ! ម៉ែប្រាប់ខ្ញុំមកម៉ែ!"

ឪពុកម្ដាយជាសត្វមិននិយាយប្រាប់ទេ លុះកូនជជីកសួរពេក ម៉ែក៏និយាយថា៖ "ម៉ែប្រាប់កូនឯងទៅចុះ ឪម៉ែកូនឯងជាមនុស្សទេ! ប៉ុន្តែបានជាម៉ែយកមកចិញ្ចឹម ព្រោះម៉ែស្វែងរកចំណីហើយឃើញឪពុកម្ដាយកូនឯងដាក់កូននៅក្បែរមាត់ស្ទឹង ម៉ែស្មានថាជាដុំសាច់ក៏ឆាបយកមកធ្វើជាចំណី ប៉ុន្តែដល់ដឹងកូនឯងយំផាំៗដឹងជាមនុស្សបានម៉ែយកមកចិញ្ចឹម!"

---

25 វាយុភក្ស (-ភ័គ) ឈ្មោះយក្សម្នាក់នៅក្នុងរឿងរាមកេរ្តិ៍ ។ *វចនានុក្រមខ្មែរ* ទំព័រទី១១៧២, គ្រាបោះពុម្ពលើកទី៥ ១៩៦៨, វិទ្យាឋានពុទ្ធសាសនបណ្ឌិត្យ

ព្រួអញ្ចឹង កូននោះក៏ទាមទារឲ្យនាំខ្លួនមកជួបឪពុកម្ដាយបង្កើតៗ សត្វនោះក៏នាំកូនមក ដោយកូនវាដឹងក្ដី ធំ ស្រាប់តែពីរនាក់ប្ដីប្រពន្ធឃើញក៏រត់ពួនក្រោមដើមចេក ទើបសត្វវាយុកក្សហ្នឹងថា៖ "ខ្ញុំនាំកូនមកឲ្យលោកវិញទេ កុំភ័យ!"

ដឹងរឿងរ៉ាវមាណពនិងប្រពន្ធរត់ចូលមកវិញៗ ហើយសត្វវាយុកក្សប្រគល់កូនហ្នឹងទៅឲ្យឪពុកម្ដាយបង្កើតគេវិញ ហើយផ្ដាំផ្ញើថា៖ "ដល់កូនហ្នឹងពេញវ័យពេញអាយុដែលត្រូវស្ដីត្រូវដណ្ដឹង អ្នកឯងកុំចោលខ្ញុំណា តែខ្ញុំមិនអាចអង្គុយបត់ជើងទេ មានតែចងដៃទុកឲ្យផង ខ្ញុំនឹងមកបង្គាប់ការដែរ! ដល់ពេលរៀបការហ្នឹងក៏អញ្ចឹងដែរ ត្រូវតែរៀបចងដៃសិន ខ្ញុំនឹងមកបង្គាប់ផ្លែឈើ៣៦មុខ!"

ហេតុដូច្នេះហើយបានជាមានផ្លែឈើ៣៦មុខ ហើយបានជាមានដៃនៅពេលរៀបមង្គលការ ព្រោះសត្វវាយុកក្សមិនអាចអង្គុយលើកន្ទេលបានទេ បានតែទុំលើដៃៗ
ដៃហ្នឹងគឺចង់សំដៅលើអ្វីដែលគេចងឲ្យមេបាផ្អែកៗ ពេលចងដៃ គេមកជុំហើយក៏បង្គាប់ដល់កូនៗ ហើយរបស់របរដែលត្រូវជូនកូនគេ ជូនម្ដាយគេត្រូវតែជាផ្លែឈើ៣៦មុខ ព្រោះសត្វនោះចិញ្ចឹមកូនគ្មានបាយទេ មានតែផ្លែឈើ៣៦មុខៗ ញ្ចឹងបានជាត្រូវរៀបចាំផ្លែឈើ៣៦មុខក្នុងពេលរៀបមង្គលការមកទល់សព្វថ្ងៃហ្នឹងៗ

ដល់ពេលកូនហ្នឹងរៀបការ ជួបជុំគ្នាហើយ និយាយពីមាណពនិងប្រពន្ធហ្នឹងក៏ស្លាប់ទៅៗ ដល់ពេលគេសូត្រមន្ត គេក៏យកដើមចេកហ្នឹងមកជំនួសជាតំណាងមាណពនិងប្រពន្ធ ព្រោះពេលដែលប្ដីប្រពន្ធពីរនាក់នោះខ្លាចសត្វវាយុកក្សបានរត់ទៅពួននៅដើមចេកនោះ អញ្ចឹងហើយបានជាមានដាក់ដើមចេកនៅពេលសូត្រមន្តៗ

ការរាប់ផ្លែឈើទាំង៣៦មុខហ្នឹង បើតាមពិតទៅ វាអត់ពិតទេ មិនគ្រប់ទេៗ ប៉ុន្តែដល់មកជំនាន់ក្រោយមក ទើបតែមានផ្លែឈើ៣៦មុខៗ ជាក់ស្ដែងក្នុងសង្គមសម័យ១៩៧៩មក ពីដើមគេយកនំ អន្សម នំគម នំខ្វិ នំប្រំ នំចក នំពិបាំង នំម៉ឹនត្រាវ នំអីៗទាំងអស់ ហ្នឹងយកជំនួសអាផ្លែឈើនេះ តែឥឡូវមានដែរ អន្សមតិចតួច នំគមអីតិចតួច ផ្លែឈើមានមែន តែវាអត់គ្រប់ទេ ចប់ប៉ុណ្ណឹង៕

# ១៨- រឿងផ្កាស្លាបី

## និទានដោយតា ឆាយ កង [26]



26 នៅភូមិអង្គតាចន្ទ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

លោកតាដូចជារឿងទាក់ទងនឹងផ្កាស្វាបីមានតំណាលដូចម្ដេចដែរ?

ឈ្មោះផ្កាស្វាបី?

ចាស៎

រឿងផ្កាស្វាបី បើនិយាយទៅ និយាយអំពីបុរសបួននាក់ទៅរៀន។ គេជាមិត្តសម្លាញ់គ្នា។ មួយរៀនបាញ់ មួយរៀនប្រស់ជប់ មួយរៀនទាយ មួយរៀនមុជទឹក។ លុះរៀនចេះចប់ទាំងអស់គ្នាក៏បបួលនាំគ្នាដើរមក។ រួចក៏ដើរមកដល់មាត់ទន្លេ។

អ្នកទាយគេបើកក្បួនមើលគេថា៖ "យី! បន្តិចទៀតមានសត្វវាយុកក្សមកពាំស្ត្រីម្នាក់ហោះកាត់ទីហ្នឹង!"

បើអញ្ចឹងអ្នកបាញ់ថា៖ "ទុកឲ្យអញបាញ់ៗ!"

មួយស្របក់ក្រោយមកក៏មានសត្វវាយុកក្សពាំនាងស្ត្រីហ្នឹងមកមែនៗ អ្នកបាញ់គេយឹតធ្នូផាំងត្រូវកន្ទុយស្វាប ធ្លាក់ខ្ទាក់ក្នុងទឹក។ មិនដឹងអ្នកណាទៅយក មានតែអ្នកចេះមុជទឹកទើបហ៊ានមុជ គេក៏មុជហែលពរនាងពីក្នុងទឹកមក។ មកដល់លើគោក អ្នកប្រស់ គេក៏ប្រស់នាងឲ្យរស់ឡើងវិញទៅ។

រួចមក អ្នកទាំងបួននាក់ក៏ជណ្ដើមគ្នា ព្រោះស្រលាញ់នាងនោះទាំងអស់គ្នា។ អ្នកទាយគេថាគេប៉ិនទាយ អ្នកបាញ់គេថាគេបាញ់បាន អ្នកមុជក៏គេថាគេទៅពរមក អ្នកប្រស់គេថាគេខំប្រស់។ ជណ្ដើមគ្នាមិនអស់មិនហើយ អញ្ចឹងក៏បាននាំគ្នាទៅរកអាចារ្យដើមគឺអាចារ្យទេសាបាម្នោកវិញ។ អាចារ្យទេសាបាមោក្ខកាត់សេចក្ដីថា៖ "បើអញ្ចឹងអ្នកទាំងបីនាក់គឺអ្នកទាយ អ្នកបាញ់ អ្នកប្រស់នេះមិនត្រូវបានទេ អ្នកដែលត្រូវបានគឺអ្នកមុជទឹក

ព្រោះគេបានទៅបីពរនាងពីក្នុងទឹកមក លូកដៃប៉ះសាច់ស្ត្រីហ្នឹងមុនគេ អញ្ចឹងអ្នកមុជទឹកត្រូវបាននាងនោះ។" បើអញ្ចឹងអ្នកទាំងពីរនាក់ត្រូវរកផ្កាឲ្យបានបីទងមក។ ពីដើមមានតែផ្កាដើមជម្ពូព្រឹក្ស ក៏យកផ្កានោះបីទងមក។ មួយទុកជាឪពុកគឺអ្នកទាយ អ្នកបាញ់ទុកជាម្ដាយ អ្នកប្រស់ទុកជាបង។ បើអញ្ចឹងក៏យកផ្កាជម្ពូព្រឹក្សមួយជូនទៅឪពុក មួយជូនទៅម្ដាយនិងមួយទៀតជូនទៅបង។ តែក្រោយមកគេក៏យកផ្កាស្លាមកជំនួសផ្កាជម្ពូព្រឹក្សនោះវិញ។ តែមកទល់សព្វថ្ងៃនេះក្នុងពិធីរៀបមង្គលការ ដោយសារគេពិបាករកផ្កាស្លា ទើបគេយកផ្កាដូងមកជំនួសវិញ តែគេនៅតែហៅពិធីនោះថាពិធីបាចផ្កាស្លា។

កាលជំនាន់រៀបការក្រីស្នាជាលីនោះ ពេលដែលគេប្រគល់ផ្កាស្លាទាំងបីហើយ គេចាប់ដៃអ្នកទាំងពីរនាក់ហ្នឹងជ្រលក់ក្នុងទឹកផ្តិលហើយជាការស្រេច។ ការជ្រលក់ដៃកូនក្រមុំកូនកំលោះទៅក្នុងទឹកផ្តិល ព្រោះទឹកវាត្រជាក់តំណាងឲ្យប្ដីប្រពន្ធនោះរកស៊ីមានបានត្រជាក់ត្រជុំដូចទឹក កាន់ចិត្តឲ្យត្រជាក់ដូចទឹក កុំបី មានចិត្តក្ដៅក្រហាយដាក់គ្នា៕

# ១៩- ប្រវត្តិរឿងខ្លែងឯក

## និទានដោយ លោក អ៊ុក សៅបុល [27]

ប្រវត្តិព្រេងនិទានពីរឿងខ្លែងឯកហ្នឹង តាមចាស់ៗនិទានតៗគ្នាមកថា កាលពីបុរាណមក មានព្រានដើរបរបាញ់សត្វដើម្បីចិញ្ចឹមជីវិត តែសត្វដែលបរបាញ់បានមកភាគច្រើន គាត់ច្រើនយកទៅថ្វាយស្តេច ជូនសត្វនោះនៅរស់ ជូនណាទៅងាប់ៗ ព្រានហ្នឹងមានកូនកម្លោះពីរនាក់ ហើយក្នុងសាច់រឿងហ្នឹងមិនមាននិយាយពីប្រពន្ធរបស់ព្រានទេ។ ពេលព្រានចេញបរបាញ់ ចួនគាត់ចេញទៅជាមួយកូនបង ចួនទៅជាមួយកូនប្អូន ដូរវេនគ្នាម្តងម្នាក់ៗ ព្រាននោះរស់នៅក្នុងនគរ**ជេជេនបូរី** ហើយផ្ទះគាត់នៅជាប់ហ្នឹងព្រៃកមួយៗ

នៅថ្ងៃមួយព្រានមកពីព្រៃវិញ ក៏ចាប់បានមេខ្លែងមួយ និងកូនខ្លែងមួយចេះហើរតិចៗតាមមេវា។ ពេលបានខ្លែងមកដល់ផ្ទះ អាបងយកមេខ្លែង ឯអាប្អូនយកកូនខ្លែង កូនប្រុសទាំងពីរនាក់ហ្នឹង នាំគ្នាចិញ្ចឹមបង្ហាត់ខ្លែងម្នាក់មួយៗ។ លុះថ្ងៃក្រោយមកទៀត ពេលព្រានជាឪពុកត្រលប់ពីបរបាញ់វិញ ក៏ឲ្យកូនទាំងពីរវែកយកសត្វដើរមកលក់នៅឯផ្សារ ហើយមេខ្លែងនិងកូនខ្លែងក៏ទៅជាមួយម្ចាស់វាដែរ។ ពីរនាក់បងប្អូនចែកវេនគ្នាវែកម្តងម្នាក់ ព្រោះធ្ងន់ហើយដើរផ្លូវឆ្ងាយទៀត។ អាមេខ្លែងទំលើដងវែក ឯកូនខ្លែងទំលើស្មាអ្នកណាដែលវែក។

និយាយពីស្តេចនគរជេជេនបូរីហ្នឹងមានកូនក្រមុំពីរនាក់។ រាជបុត្រីទាំងពីរក៏សុំលាមាតាបិតាមកទស្សនាជនបទ។ លុះមកដល់ គាប់ចួន ចំពេលកម្លោះទាំងពីរដែលជាកូនរបស់ព្រានប្រមាញ់យកសត្វមកលក់នៅផ្សារ

27 នៅភូមិក្រាំងធ្នុង ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ។

ដែរ រាជបុត្រីទាំងពីរឃើញកម្លោះទាំងពីរនាក់នោះស្អាត គួចចិត្តចង់និយាយជាមួយកម្លោះនោះ តែមិនដឹងធ្វើយ៉ាងម៉េចព្រោះខ្លួនជាស្ដេចមានកិត្តិយសជាក្សត្រផែនដី ក៏សំរេចឲ្យអាមាត្រពីរនាក់ទៅសួរទិញខ្លែងពីរក្បាលពីកម្លោះនោះដើម្បីយកបង្ហោះលេង មិនមែនទិញអាសត្វដែលបាញ់បានយកមកលក់នៅផ្សារទេ។

លុះសេនាបតីហ្នឹងទៅទាក់ទងជាមួយកម្លោះពីរនាក់។ អាប្អូននិងអាបងនិយាយដូចគ្នាថា៖ "ខ្ញុំមិនអាចលក់បានទេ ព្រោះខ្ញុំទាំងពីរនាក់ស្រលាញ់វាទាំងពីរ ខ្ញុំចិញ្ចឹមវាយូរហើយ។"

ប្អូនថា៖ "អាកូនខ្លែងនេះ ខ្ញុំចិញ្ចឹមវាតាំងពីតូចមកម្ល៉េះ។"

ហើយអាបងថា៖ "ហឺ មេខ្លែងនេះខ្ញុំក៏អត់លក់ដែរ ខ្ញុំស្រលាញ់វាណាស់ វាចេះណាស់ ខ្ញុំប្រើបាន អីបានឲ្យទៅខាំអីពាំអីយកមកឲ្យខ្ញុំ វាយកមកឲ្យខ្ញុំបាន ខ្ញុំទៅណាមកណា ខ្ញុំប្រើវាឲ្យនៅចាំផ្ទះ ខ្ញុំមិនអាចលក់បានទេ។"

ស្ដាប់បានដូចនេះហើយ អាមាត្រនោះក៏ទូលប្រាប់រាជបុត្រីទាំងពីរអង្គវិញតាមដំណើរដែលកម្លោះពីរនាក់ផ្ដាំមក។ រាជបុត្រីថា៖ "អញ្ចឹងមានតែជួលខ្លែងនោះមកបង្ហោះលេង។"

ឮដូចនោះ ប្រជារាស្ត្រនៅក្នុងផ្សារថា៖ "បើស្ដេចចង់ជួលសត្វនេះហើយ ហើយយើងមិនជួលឲ្យទេ ដូចជាយើងប្រឆាំងនឹងរាជបញ្ជា។"

កម្លោះទាំងពីរមានការខ្លាចរអាដែរក៏សុខចិត្តជួលខ្លែងឲ្យគេយកទៅបង្ហោះទៅតែផ្ដាំថា៖ "ដើម្បីកុំឲ្យខ្លែងហ្នឹងរឹង ហើយហើរទៅបាត់ ទាល់តែចងជើងខ្លែងនោះ។"

រួចបុត្រីទាំងពីរក៏ចាប់ផ្ដើមបង្ហោះខ្លែង បុត្រីបងកាន់ខ្លែងមួយ ឯប្អូនកាន់ខ្លែងមួយ ពេលដែលបង្ហោះទៅ

បុត្រីនោះបង្ហោះទាញកន្ទ្រាក់ខ្សែខ្លាំងពេក ធ្វើឲ្យកម្មោះនោះអាណិតដល់ខ្លែងនោះណាស់ ក៏ទៅជួយកាន់ខ្សែខ្លែងទប់កុំឲ្យកន្ទ្រាក់ខ្លាំងពេក ដូចជួយបង្រៀនបុត្រីទាំងពីរបង្ហោះខ្លែងអញ្ចឹង។ ខ្លែងទាំងមេទាំងកូនស្ដាប់បញ្ជាម្ចាស់វាណាស់ បើកូនព្រានព្រៃមិនឲ្យហោះទេ វាមិនហោះទេ។ កូនព្រានព្រៃបងបង្ហោះជាមួយនឹងបុត្រីបង ឯអាប្អូនបង្ហោះជាមួយបុត្រីប្អូន។ ពេលបង្ហោះយូរទៅៗ ក៏ចាប់ប៉ះដៃគ្នា ដៃរបស់កូនព្រានព្រៃនិងហត្ថារបស់បុត្រីចាប់គ្នាមើលមុខគ្នាសម្លក់សម្លឹងយូរទៅកើតជាសេក្ដីស្នេហា។ រវល់តែសាសងស្នេហា ហើយចេះតែទាញខ្លែងចុះឡើងៗ មិនបានមើលថាខ្លែងយ៉ាងណាឬយ៉ាងណាទេ។ ដល់ខ្លែងហោះខ្ពស់ទៅ វាទាញមកវិញ ដល់ទាញខ្លែងចុះទាញឡើងៗទៅ ខ្លែងទាំងមេទាំងកូនហត់ខ្លាំងមែនទែន ស្រេកកាក់ៗៗៗ ធ្វើឲ្យបំពង់កវាហត់ខ្លាំងប្រឹងដកដង្ហើមផង ប្រឹងទទះស្លាបផង យូរៗទៅខ្លែងទាំងមេទាំងកូនដាច់ខ្យល់ងាប់ទៅ។

ពេលខ្លែងទាំងពីរស្លាប់ទៅ បុត្រីទាំងពីរមិនដឹងធ្វើយ៉ាងម៉េចក៏ថ្វាយដំណឹងនេះដល់មាតាបិតាក្នុងវាំង។ មាតាបិតាឯណេះថា៖ "មានតែយកកូនព្រានព្រៃធ្វើប្ដីទៅ!"

អញ្ចឹងហើយទើបស្ដេចរៀបអភិសេកបុត្រីខ្លួនទាំងពីរទៅកម្លោះកូនព្រានព្រៃពីរនាក់នោះដែរ។ បងរៀបការជាមួយបុត្រីបង ប្អូនរៀបការជាមួយបុត្រីប្អូន។

បីថ្ងៃក្រោយមក ដើម្បីរំលឹកដល់អនុស្សាវរីយ៍បង្ហោះខ្លែងរបស់បុត្រីស្ដេចផែនដីនិងកូនព្រានព្រៃបានជាប្ដីប្រពន្ធនឹងគ្នាដូច្នេះ គេក៏យកឫស្សីខ្វែងជាសញ្ញាបូក ពាសដោយកំណាត់ធ្វើជាស្លាបតំណាងឲ្យសត្វខ្លែង។ គេដាក់ស្លាបខាងលើមានរាងធំតំណាងឲ្យមេខ្លែង ហើយស្លាបខាងក្រោមតូចមានរាងតូចតំណាងឲ្យកូនខ្លែងទៅ ហើយខ្សែវែង ដែលធ្លាក់ចុះមកខាងក្រោមទាំងពីរចូលគ្នាបង្កើតបានជាកន្ទុយខ្លែង អ្នកខ្លះថាជើងទា។ អាផ្អឹង

មេខាងលើនោះ គេធ្វើបូករបៀបកោងនៅខាងក្រោមឯក[28]ហ្នឹងតំណាងឲ្យខ្សែទាំងមូល ឯឯកខាងលើជងឬស្សី អណ្ដាតផ្ដៅគេដាក់ផ្កាយសូត្រ ផ្កាយអំបោះ ផ្កាយម្នាស់ ឬផ្កាយនីឡុងសារ៉ូសព្វថ្ងៃ នៅតែមនោះគេបិទក្រមួន គេដាក់វាឲ្យឮសម្លេងដូចខ្សែស្រែកមែនទែនៗ

ហេតុនេះហើយ បានជាយើងមានខ្លួបទិវាលេងខ្សែតាំងពីពេលនោះមករហូត ហើយមានទំនៀមមួយថា មុននឹងបានគ្នាជាប្ដីប្រពន្ធ កូនកម្លោះត្រូវចេះធ្វើខ្សែឲ្យបានល្អត្រឹមត្រូវនិងមានឯកឮសូរសម្លេងពិរោះរណ្ដំទៀតផង ទើបគេលើកកូនឲ្យ បើកាលណាធ្វើខ្សែមិនទាន់ល្អទេ គេមិនព្រមលើកកូនឲ្យទេ៕

28 ឯកពេលនេះមិនមែនបកប្រែថា "មួយ" ទេ គឺមានន័យថា "តន្ត្រី" មកពីពាក្យបាលី សំស្ក្រឹតមានន័យថាឧបករណ៍ភ្លេងដែលមានខ្សែរឹតបន្ធូរ បន្តឹងទៅតាមសម្លេង ហើយឯកនេះមានខ្សែ គេរឹតអណ្ដាតឯក ចងខ្សែឲ្យជាប់ទាំងសងខាងឲ្យតឹង ដល់អណ្ដាតនោះក្ដៅវាឲ្យឮសម្លេងស្រួយ បើចងធូរបន្តិចសម្លេងវាគ្រលៗ

# បញ្ជីឈ្មោះប្រជាជនដែលបានផ្តល់បទសម្ភាសន៍

| | |
|---|---|
| លោកតា **ឆាយ កង** | អាយុ៨២ឆ្នាំ នៅភូមិអង្គតាចន្ទ័ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ |
| លោកតា **ថោង ហ៊ុំ** | អាយុ៦៦ឆ្នាំ នៅភូមិសំរោងស្នោ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| លោកតា **ទូច កាយ** | អាយុ ៧៧ឆ្នាំ នៅភូមិតាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង |
| កុមារី **ផន ស្រីលក្ខណ៍** | អាយុ ១២ឆ្នាំ ភូមិត្រពាំងជ្រៃ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ |
| ព្រះតេជគុណ **ម៉ោ ម៉េង** | ព្រះជន្ម ២៦ឆ្នាំ នៅវត្តខ្នារ ភូមិខ្នារ ឃុំស្នាមព្រះ ស្រុកបាកាណ ខេត្តពោធិ៍សាត់ |
| លោក **ម៉ៅ សោភ័ណ** | អាយុ ៥៧ឆ្នាំ ភូមិកំពែងស្វាយឃុំស្នាមព្រះ ស្រុកបាកាណខេត្តពោធិ៍សាត់ |
| លោកតា **រឹម** | អាយុ៦៨ឆ្នាំ ភូមិអូររំចេក ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ |
| លោក **លឹម គឹមអ៊ិន់** | អាយុ៥៤ឆ្នាំ នៅភូមិវាល ឃុំវាល ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ |
| លោក **សោម នៅ** | អាយុ ៥៩ឆ្នាំ ភូមិទន្លេបាទី ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ |
| លោកយាយ **ហួន** | អាយុ៧០ឆ្នាំ ភូមិឃ្លាំងប្រាំ ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ |
| ព្រះតេជគុណ **អៀ សុផន** | ព្រះជន្ម ៣០ឆ្នាំ នៅវត្តពោធិវាមហៅវត្តប៉ាហ៊ី ភូមិប៉ាហ៊ី សង្កាត់ប៉ៃលិន ខ័ណ្ឌប៉ៃលិន ក្រុងប៉ៃលិន |
| លោកតា **អ៊ិន អៀន** | អាយុ៦៨ឆ្នាំ ភូមិសំបួរមាសខ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម |
| មីង (មិនស្គាល់ឈ្មោះ) | នៅភូមិត្រពាំងជ្រៃ ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ |